00508609

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
លេខ/No: D345/5/2
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 04 / 05 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦០) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អង្គជំនុំជម្រះ: ~~សម្ងាត់ / Confidential / Confidentiel~~ CR

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public CR 29/07/2010

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹង ការអនុវត្តន៍ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ

---

**<u>អ្នកដាក់ឯកសារ:</u>**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**<u>អ្នកទទួលឯកសារ:</u>**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING, QC

**មេធាវីការពារក្តី:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS
លោក ស សូវ៉ាន
លោក Jacques VERGÈS
លោក ការ សាវុត្ថ
លោក François ROUX
លោក អាង ឧត្តម
លោក Michael G.KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី
លោក ឡោ ជុនធី

00508610



*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦០)*

ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហ្វួត វុទ្ធី

កញ្ញា SILKE Studzinsky
លោក គង់ ពិសី
លោក ហុង គីមសួន
លោក យុង ផានិត
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ("ស.ព") ដាក់ចម្លើយតបរបស់ខ្លួន ("ចម្លើយតប") ទៅនឹងបណ្តឹងឧទ្ធរណ៍ ("បណ្តឹងឧទ្ធរណ៍") ដែលបានដាក់ដោយជនត្រូវចោទ អៀង សារី ("ដើមបណ្តឹងឧទ្ធរណ៍")[1] ដែលស្វែងរកឱ្យមានការផ្លាស់ប្តូរនៅលើ "ដីកាសម្រេច[2] ("ដីកាដែលបានតវ៉ា") របស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលបានបដិសេធនៅលើសំណើពីររបស់ខ្លួន ស្តីពីការអនុវត្តន៍នៃការទទួលខុសត្រូវរបស់អ្នកបញ្ជា ("CR") ឬការទទួលខុសត្រូវរបស់ថ្នាក់លើ នៅ អ.វ.ត.ក ។ ដើមបណ្តឹងឧទ្ធរណ៍ ស្នើឱ្យអង្គបុរេជំនុំជម្រះប្រកាសថា CR មិនអាចអនុវត្តបាននៅ អ.វ.ត.ក ។ សហព្រះរាជអាជ្ញា ("ស.ព") សន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ គួរតែត្រូវបានបដិសេធចោលដោយសារមិនអាចទទួលយកបាន ឬគ្មានអង្គសេចក្តី ទោះក្នុងករណីណាក៏ដោយ ។

២. បណ្តឹងឧទ្ធរណ៍តវ៉ាអំពីការអនុវត្តន៍ទ្រឹស្តី CR ដោយជំទាស់ជាអាទិ៍ថា (១) ការអនុវត្តន៍នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលដូច្នេះ មិនមែនជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិ ("CIL") ទេ នៅក្នុងអម្លុងពេលដែលបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ បានប្រព្រឹត្តឡើង ។ (២) សន្មត់ថាបើអនុវត្តមែន អ.វ.ត.ក គឺជាតុលាការក្នុងស្រុកមួយរបស់កម្ពុជា ដែលមិនអាចអនុវត្តបានចំពោះការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលមាននៅក្នុងយុត្តាធិការអន្តរជាតិនានាឡើយ និង (៣) ដោយសន្មត់បន្តទៀតថាបើសិនជាត្រូវអនុវត្តមែន ទ្រឹស្តីCR ត្រូវបានរារាំងដោយគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* ដោយហេតុថា វាមិនបានឱ្យនិយមន័យឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យការអនុវត្តន៍របស់វាអាចឱ្យគេព្យាករណ៍បាននៅប្រទេសកម្ពុជា ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ។

៣. ជាបឋម ស.ព សន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍គ្មានសិទ្ធិប្តឹងឧទ្ធរណ៍តាមវិធាន ៧៤.៣.ក នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលបានតវ៉ានេះទេ និងថាហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបានទេ ។

៤. បើអង្គបុរេជំនុំជម្រះរកឃើញថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន និងយកបណ្តឹងឧទ្ធរណ៍មកពិចារណានៅលើអង្គសេចក្តីរបស់វា ស.ព សន្និដ្ឋានថា (១) ទ្រឹស្តី CR គឺជាទម្រង់នៃការទទួល

[1] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ, *សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦០)*, ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០, ឯកសារលេខ: D345/5/1, ERN 00491231-00491261 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

[2] ដីកាសម្រេចលើសំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេកើយ នៅ អ.វ.ត.ក, *សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស,* សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០, ឯកសារលេខ: D345/4, ERN 00487605-00487608 [*ចាប់ពីនេះតទៅហៅថា* ដីកា] ។

ខុសត្រូវដែលត្រូវបានទទួលស្គាល់ជាប្រវត្តិសាស្ត្រ ហើយជាផ្នែកមួយនៃ ទ្រឹស្តី CR ក្នុងចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៩ នៅពេលដែលបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ បានប្រព្រឹត្តឡើង ។ (២) ទ្រឹស្តីCR អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយហេតុថាតុលាការនេះត្រូវបានផ្តល់អាណត្តិឱ្យផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងមានផ្ទុកនូវ "សញ្ញាបង្ហាញ" របស់តុលាការព្រហ្មទណ្ឌអន្តរតួបនីយកម្ម ដូចអង្គបុរេជំនុំជម្រះបានសម្រេច; និងជាចុងក្រោយ (៣) គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* ឬគោលការណ៍នីត្យានុកូលភាព មិនបានរារាំងដល់ការអនុវត្តន៍នៃទ្រឹស្តី CR ទេ ដោយហេតុថា គោលការណ៍នេះមិនតម្រូវឱ្យមាននិយមន័យច្បាស់លាស់ ស្តីពីទម្រង់នៃការទទួលខុសត្រូវទេ - រួមទាំងគ្រោងការណ៍ទាំងអស់របស់វា - ដើម្បីកំណត់និយមន័យក្នុងពេល នៃព្រឹត្តិការណ៍ដែលមានបទឧក្រិដ្ឋ ។

## ២. អំណះអំណាងខាងផ្នែកនីតិវិធី
## បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន

៥. តាមការសង្កេតជាបឋម ស.ព សន្និដ្ឋានថា វាជាការបើកចំហរដល់អង្គបុរេជំនុំជម្រះដើម្បីប្រកាសថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយហេតុថាមិនមានចែងនៅក្នុងអនុវិធាន៧៤.៣ និងមិនបានលើកនូវបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងឧទ្ធរណ៍ អំពីការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ។

៦. ដូចស.ច.ស បានកត់សំគាល់យ៉ាងត្រឹមត្រូវលើសំណើធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះ លក្ខណៈនៃសំណើនេះ គឺពិតជាសំណើបកស្រាយច្បាប់[3] ។ ពាក្យពេចន៍នៅក្នុងសំណើ ("ដើម្បីច្រានចោលការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវCR នៅចំពោះមុខ អ.វ.ត.ក")[4] មិនបានកែប្រែលក្ខណៈជាមូលដ្ឋាននៃសំណើនេះទេ: ការសុំឱ្យច្រានចោលទម្រង់នៃការទទួលខុសត្រូវមួយ គឺគ្រាន់តែជាមធ្យោបាយយ៉ាងសាមញ្ញមួយផ្សេងនៃសំណើសុំឱ្យ*ប្រកាសថា* ទម្រង់នៃការទទួលខុសត្រូវមិនអាចទទួលយកបាន[5] ។ ក្របខ័ណ្ឌនីតិវិធីរបស់ អ.វ.ត.ក មិនតម្រូវឱ្យ ស.ច.ស ចេញដីកាបកស្រាយច្បាប់ទេ[6] ហើយក៏ស៊ីសង្វាក់គ្នានឹងអ្វីដូចបានពោលនេះដែរដោយវាមិនមានចែង

---

[3] ដីកា, កថាខ័ណ្ឌទី១០ ។

[4] *សំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស*, ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារលេខ: D345/2, ERN 00475513-00475527, ទំព័រទី១៤ [*ចាប់ពីនេះតទៅហៅថា* សំណើ] ។

[5] សាលក្រមបកស្រាយ ត្រូវបានកំណត់និយមន័យតាមវចនានុក្រម BLACK LAW DICTIONARY 859 (Thomson West, បោះពុម្ពលើកទី៨, ឆ្នាំ២០០៤) ថាជា: "ការវិនិច្ឆ័យជាប់ចំណងមួយ ដែលកំណត់អំពីសិទ្ធិ និងទំនាក់ទំនងខាងផ្លូវច្បាប់ផ្សេងទៀតរបស់គូភាគីនានា ដោយពុំចាំបាច់មានការផ្តល់ជូន ឬការបញ្ជាឱ្យមានការពង្រឹងការអនុវត្តន៍" ។

[6] អនុលោមតាមអនុវិធាន៥៥.៥ សម្រាប់ផ្នែកពាក់ព័ន្ធ ចែងថា សហចៅក្រមស៊ើបអង្កេតអាច... "តាមការចាំបាច់ ចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរ" ។ វិធានមិនបានតម្រូវឱ្យចៅក្រមចេញដីកានានាដើម្បីប្រកាសច្បាប់ត្រូវអនុវត្តទេ ជាក់ស្តែងក្រៅពីផ្នែកនៃដីកាដំណោះស្រាយ ។

ពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើការបកស្រាយច្បាប់ណាមួយ ដែលអាចត្រូវបានចេញដោយស.ច.ស ។

៧. ឲ្យជាក់លាក់ជាងនេះ បណ្តឹងឧទ្ធរណ៍នេះមិនស្ថិតក្នុងក្រុមនៃបណ្តឹងឧទ្ធរណ៍ ដូចបានកំណត់នៅក្នុងអនុវិធាន ៧៤.៣.ក ទេ ពីព្រោះត្រឹមតែសេចក្តីសម្រេចមួយនៅលើភាពអាចរកបាននៃទម្រង់នៃការទទួលខុសត្រូវ មិនអាចស្មើនឹង "ការបញ្ជាក់អះអាងលើយុត្តាធិការ" របស់តុលាការបានទេ ។ ស.ព សន្និដ្ឋានថា មានភាពខុសគ្នារវាង ១) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង*ការបញ្ជាក់អះអាងលើយុត្តាធិការ* ដែលធ្លាក់ទៅក្នុងកថាខណ្ឌទី ៧៤.៣.ក និងដែលអាចបណ្តាលឲ្យមានការផុតរលត់នៃកិច្ចដំណើរការនីតិវិធី ប្រសិនបើយល់ស្របតាម; និង ២) ការកំណត់អំពីបញ្ហាផ្លូវច្បាប់សំដៅភាពអាចរកបាននៃទម្រង់នៃការទទួលខុសត្រូវមួយក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវមួយចំនួន ហើយក៏មិនស្មើនឹងការបញ្ជាក់អះអាងអំពីយុត្តាធិការរបស់តុលាការដែរ ។

៨. វិធាន ២១ នៃវិធានផ្ទៃក្នុង មិនតម្រូវឲ្យអង្គបុរេជំនុំជម្រះត្រូវយកតាមការបកស្រាយដ៏ទូលំទូលាយមួយអំពីសិទ្ធិប្តឹងឧទ្ធរណ៍ ក្រោមវិធាន ៧៤.៣.ក របស់ជនត្រូវចោទទេ[7] ។ សិទ្ធិរបស់ជនត្រូវចោទត្រូវបានថែរក្សាយ៉ាងពេញទំហឹងតាមលទ្ធភាពរបស់គាត់ដើម្បី ១) ធ្វើសារណាអំពីច្បាប់ជាធរមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលណាបទចោទ និងការកំណត់បទចោទជាក់លាក់ត្រូវបានចេញដោយ ស.ច.ស; និង ២) ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះតុលាការកំពូល[8] ។

៩. បើអង្គបុរេជំនុំជម្រះចូលពិនិត្យលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ វានឹងជាការអនុញ្ញាតយ៉ាងមានប្រសិទ្ធភាពឲ្យគូភាគីនានាស្នើសុំឲ្យបកស្រាយ (តាមរយៈ ស.ច.ស និងអង្គបុរេជំនុំជម្រះ) នៅលើបញ្ជីរាយឈ្មោះពេញលេញនៃបទឧក្រិដ្ឋ ទម្រង់នៃការទទួលខុសត្រូវ និងសិទ្ធិស្របច្បាប់ និងកាតព្វកិច្ចផ្សេងទៀតដែលមាននៅក្រោមច្បាប់ អ.វ.ត.ក[9] ។ ផ្ទុយពីនេះ ច្បាស់ណាស់ថា មិនស៊ីសង្វាក់គ្នានឹងក្របខ័ណ្ឌនីតិវិធីរបស់ អ.វ.ត.ក ទេ ពីព្រោះសូម្បីតែអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលក៏មិនជាប់ចំណងទៅនឹងការសម្រេចតាមផ្លូវច្បាប់របស់ ស.ច.ស ឬ

---

[7] *សូមអាន ឧទាហរណ៍ សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៧), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០, ឯកសារលេខ: D130/10/12, ERN 00432775-00432784, ទំព័រទី២១-២៩ ។ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារលេខ: A190/I/20, ERN 00283249-00283262, ទំព័រទី៣៤-៥០ ។

[8] អនុវិធាន១០៤.១ ។

[9] *សូមអាន ឧទាហរណ៍ ពាក្យសុំរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស, ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០, ឯកសារលេខ: D378, ERN 00498540-00498552 ។

អង្គបុរេជំនុំជម្រះដែរ[10] ។ អាស្រ័យហេតុនេះ តាមនីតិវិធី បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ និងមិនគួរឱ្យមានសវនាការផ្ទាល់មាត់ឡើយ ។

## សវនាការដេញដោលផ្ទាល់មាត់មិនចាំបាច់ទេ

១០. ដើមបណ្តឹងឧទ្ធរណ៍ ស្វែងរកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ដោយសារតែ "បញ្ហាអង្គច្បាប់សុទ្ធសាធ" ដែលត្រូវលើកយកមកតវ៉ា, ព័ត៌មានសម្ងាត់នឹងមិនលើកយកមកពិភាក្សាទេ ហើយសាធារណៈជនទូទៅ នឹងទទួលបានផលប្រយោជន៍ពីសវនាការដេញដោលផ្ទាល់មាត់នេះ[11]។ ស.ព សង្កេតឃើញថា សិទ្ធិទទួលបានសវនាការផ្ទាល់មាត់ មិនមែនជាសិទ្ធិដាច់ខាតទេ ហើយឯកសារជាមូលដ្ឋានរបស់តុលាការនេះ គ្រាន់តែបានធានាចំពោះសិទ្ធិនេះនៅក្នុងពេលសវនាការតែប៉ុណ្ណោះ មិនមែននៅក្នុងដំណាក់កាលមុនសវនាការទេ[12] ។ ទោះក្នុងករណីណាក៏ដោយ សិទ្ធិទទួលបាននូវសវនាការណាមួយ មិនចាំបាច់ទាល់តែមានសវនាការផ្ទាល់មាត់ឡើយ - គេអាចរាប់បញ្ចូលទាំងសេចក្តីសម្រេចដែលមានសំអាងហេតុ និងជាសាធារណៈណាមួយនៅលើសេចក្តីថ្លែងសំអាងតែប៉ុណ្ណោះ[13] ។ បើសិនគូភាគីនានាត្រូវបានគេផ្តល់ឱកាសឱ្យដាក់ករណីរបស់គេជាលាយលក្ខណ៍អក្សរ និងឱ្យឆ្លើយតបទៅនឹងសារណារបស់គូភាគីដទៃទៀត នោះគេអាចធ្វើការសន្និដ្ឋានបានថាលក្ខខណ្ឌតម្រូវអំពីភាពត្រឹមត្រូវយុត្តិធម៌ ត្រូវបានអនុវត្តតាមរួចទៅហើយៗសវនាការដេញដោលផ្ទាល់មាត់ណាមួយមិនចាំបាច់ឱ្យមានទេ[14] ។

---

[10] ជាឧទាហរណ៍ សហព្រះរាជអាជ្ញាកត់សំគាល់ថា ក្នុងការសម្រេចលើបញ្ហាទាក់ទិននឹងនីត្យានុកូលភាពអំពីការឃុំខ្លួនរបស់ជនជាប់ចោទកាលពីលើកមុន នៅក្នុងសំណុំរឿងលេខ០០១, អង្គជំនុំជម្រះសាលាដំបូងបានប្រាសចាកពីហេតុផលដែលបានអនុម័តដោយអង្គបុរេជំនុំជម្រះនៅលើបញ្ហាដូចគ្នា ។ *សូមអាន សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ*, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ (អបជ២៧), អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩, ឯកសារលេខ: D288/6.39/5, ERN 00338832-00338846, ទំព័រទី១៦ ។ *សម្រាប់ការប្រៀបធៀប សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច*, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០១), អង្គបុរេជំនុំជម្រះ, ឯកសារលេខ: D5/45, ERN 00154284-00154302, ទំព័រទី១៨-២១ ។

[11] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី៤ ។

[12] *សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច ទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងក្នុងក្របខ័ណ្ឌនៃសំណុំរឿង អបជ ២៤ និង ២៥*, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៤), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩, ឯកសារលេខ: D164/4/9, ERN 00388749-00388756, [*ចាប់ពីនេះតទៅហៅថា* សេចក្តីសម្រេចស្តីពីសវនាការផ្ទាល់មាត់] ។

[13] *Jussila ទល់នឹង ប្រទេសហ្វាំងឡង់*, សាលក្រម, ២៣ វិច្ឆិកា ២០០៦, ពាក្យសុំលេខ ៧៣០៥៣/០១, អង្គជំនុំជម្រះខាគធំនៃសវនាការរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌទី៤១ ។

[14] *Vilho Eskelinen និងគូកន ទល់នឹង ប្រទេសហ្វាំងឡង់*, សាលក្រម, ១៩ មេសា ២០០៧, ពាក្យសុំលេខ ៦៣២៣៥/០០, អង្គជំនុំជម្រះខាគធំនៃសវនាការរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌទី៧៤ ។

១១. ស.ព យល់ស្របថា សាធារណៈជនទទួលបានផលប្រយោជន៍ពីកិច្ចដំណើរការនីតិវិធីដោយចំហររបស់តុលាការនៅចំពោះមុខ អ.វ.ត.ក ប៉ុន្តែតម្លាភាពស្រដៀងគ្នាអាចសម្រេចបានដែរ តាមរយៈការផ្សព្វផ្សាយដល់សាធារណៈជននូវសេចក្តីថ្លែងសំអាង និងសេចក្តីសម្រេចនានារបស់តុលាការ។ តាមពិត អង្គបុរេជំនុំជម្រះបានដាក់គ្រប់របកគំហើញរបស់គូភាគីទាំងអស់ នៅចំពោះមុខខ្លួនយ៉ាងទៀងទាត់ រួមទាំងសេចក្តីសម្រេចនានាជាបន្តបន្ទាប់របស់ខ្លួន នៅលើវ៉ិបសាយរបស់ អ.វ.ត.ក ។ អង្គជំនុំជម្រះ កម្រប្រាសចាកពីសកម្មភាពនៃការផ្សព្វផ្សាយដល់សាធារណៈជន នូវឯកសាររបស់តុលាការនេះណាស់ វៀរលែងតែផលប្រយោជន៍របស់គូភាគី(ជាពិសេសរបស់ចុងចោទ)ត្រូវទទួលរងការប៉ះពាល់[15] ។

១២. ទម្លាប់អនុវត្តច្បាស់លាស់ និងដែលស៊ីសង្វាក់គ្នាមួយបានបង្ហាញខ្លួនឡើងទាក់ទិននឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងសវនាការផ្ទាល់មាត់ ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យមានសវនាការផ្ទាល់មាត់ទាំងអស់លើកលែងតែមួយប៉ុណ្ណោះនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន[16] ដោយសារតែបណ្តឹងឧទ្ធរណ៍ទាំងនោះអាចនាំដល់ការផុតរលត់នៃកិច្ចដំណើរការនីតិវិធី និងការដោះលែងចុងចោទណាម្នាក់ជាយថាហេតុ[17] ។ អាស្រ័យហេតុនេះ រហូតមកដល់ពេលនេះ សេរីភាពរបស់ចុងចោទ ហាក់ដូចជាឧត្តមភាពនៃការពិចារណានៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ថាតើត្រូវបើកសវនាការផ្ទាល់មាត់ឬអត់[18] ។

១៣. ក្នុងសេចក្តីសម្រេចមួយនាពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះនៅតែប្រកាន់ជំហរថា នៅពេលណាខ្លួនមានព័ត៌មានគ្រប់គ្រាន់ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ និងជាផលប្រយោជន៍នៃយុត្តិធម៌

[15] *សេចក្តីសម្រេច អនុលោមតាមមាត្រា៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ: បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងនឹងការតែងតាំងអ្នកជំនាញ,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១០), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨, ឯកសារលេខ: A189/I/6, ERN 00207784-00207785, កថាខ័ណ្ឌទី៤ ។

[16] អង្គបុរេជំនុំជម្រះ បានស្តាប់សវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ដើមប្រឆាំងនឹងការឃុំខ្លួនទាំងប្រាំរបស់ជនជាប់ឃុំឃាំងទាំងប្រាំនាក់នៃតុលាការនេះ ។ បន្ទាប់ពីពេលនោះមក អង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនលើកទីមួយរបស់ អៀង ធីរិទ្ធ, អៀង សារី និង ខៀវ សំផន នៅក្រោយពីសវនាការផ្ទាល់មាត់ ។ ដោយមានការព្រមព្រៀងរបស់គូភាគីនានា បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនលើកទីមួយរបស់ នួន ជា ត្រូវបានសម្រេចនៅលើតែសេចក្តីថ្លែងសំអាងជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ។ អង្គបុរេជំនុំជម្រះ ក៏បានស្តាប់សវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនលើកទីពីររបស់ អៀង សារី (ថ្ងៃទី១១ កុម្ភៈ ២០១០), ខៀវ សំផន (ថ្ងៃទី១២ កុម្ភៈ ២០១០) និង អៀង ធីរិទ្ធ (ថ្ងៃទី១៥ កុម្ភៈ ២០១០) ។

[17] *សេចក្តីសម្រេចលើពាក្យសុំឲ្យមានសវនាការជាសាធារណៈរបស់ ខៀវ សំផន,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារលេខ: A190/I/8, ERN 00226251-00226254, កថាខ័ណ្ឌទី៨ ។ ការណ៍នេះវាឆ្លុះបញ្ចាំងពីវិធាន៧៧.៦ ដែលថា សវនាការជាសាធារណៈអាចត្រូវបានធ្វើឡើង "ជាពិសេសនៅពេលដែលសំណុំរឿងនោះត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ [អង្គបុរេជំនុំជម្រះ] ខ្លួន" ។

[18] *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារលេខ: C26/5/13, ERN 0027631-0027633 ។

ក្នុងការដំណើរការឲ្យបានឆាប់រហ័សក្នុងកិច្ចការណាមួយ អង្គជំនុំជម្រះអាចអនុវត្តដូច្នេះបានដោយពុំចាំបាច់មានសវនាការដេញដោលផ្ទាល់មាត់ទេ[19] ។ ស.ព សន្និដ្ឋានថា វាជាប្រយោជន៍នៃយុត្តិធម៌ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។ ហេតុដូចនេះ ស.ព សូមស្នើឲ្យអង្គបុរេជំនុំជម្រះ បដិសេធចោលសំណើឲ្យមានសវនាការដេញដោលផ្ទាល់មាត់របស់ដើមបណ្តឹងឧទ្ធរណ៍នេះ ។

**ការខកខានមិនបានលើកអំណះអំណាងនានាដែលបានដាក់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ**

១៤. ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើលើកទីមួយ[20] និងសំណើទីពីរជាជម្រើសមួយផ្សេង[21] តែសំណើទាំងពីរ គឺសុទ្ធតែសំអាងនីត្យានុកូលភាពនៃការអនុវត្តន៍ទ្រឹស្តី CR នៅ អ.វ.ត.ក ទាំងអស់ ។ ទោះបីជាអំណះអំណាងនៅក្នុងសារណាទាំងពីរទាក់ទងគ្នាទៅវិញទៅមកក៏ដោយ ក៏សារណានីមួយៗបានលើកឡើងនូវបញ្ហាខុសៗគ្នា ។ សារណាទាំងពីរត្រូវបានធ្វើឡើងបន្ទាប់ពី ស.ច.ស បានបដិសេធលើសំណើមួយធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ដែលសុំបន្ថែមចំនួនទំព័រសម្រាប់ដាក់សារណាតែមួយ[22]។ ស.ច.ស បានរកឃើញថាការដាក់សំណើទាំងពីរជាបន្តបន្ទាប់យ៉ាង ប្រកិតគ្នាដូច្នេះ ដោយសារ “មិនបានយកចិត្តទុកដាក់” និង “បានគេចវះពី” សេចក្តីបង្គាប់របស់ ស.ច.ស ឲ្យដាក់អំណះអំណាងទាំងអស់របស់ដើមបណ្តឹងឧទ្ធរណ៍ ស្តីពីប្រធានបទនេះនៅក្នុងការដាក់ឯកសារតែមួយ[23] ។ ទន្ទឹងគ្នានេះ ស.ច.ស មិនបានពិចារណា និងសម្រេចនៅលើសំណើទីពីរដែលបានធ្វើតាមរបៀបផ្សេងនេះទេ[24] ។

១៥. ស.ព កត់សំគាល់ឃើញថា បញ្ហាដែលបានលើកនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ យកតម្រាប់តាមបញ្ហាទាំងអស់ដែលបានលើកឡើងរួចហើយនៅក្នុងសំណើទីមួយ និងសំណើទីពីរដែលធ្វើតាមរបៀបផ្សេងនោះ ។ ស.ព សន្និដ្ឋានថា អង្គបុរេជំនុំជម្រះគួរតែពុំចាំបាច់យកចិត្តទុកដាក់អំពីអំណះអំណាងដែលបានលើកក្នុងបណ្តឹងឧទ្ធរណ៍នេះ ដែលមានផ្ទុកក្នុងសំណើទីពីរដែលបានធ្វើឡើងតាមរបៀបផ្សេងនោះទេ ។ ដើមបណ្តឹងឧទ្ធរណ៍កំពុងតែប៉ុនប៉ងធ្វើយ៉ាងណាឲ្យបញ្ហាទាំងនេះ ត្រូវបានយកមក

---

[19] *សេចក្តីសម្រេចលើ “សំណើសុំបើកសវនាការសួរដេញដោលផ្ទាល់មាត់” លើបណ្តឹងឧទ្ធរណ៍ អបជ២៤ និងអបជ២៥,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៤), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩, ឯកសារលេខ: D164/4/3, ERN 00363528-00363530 ។

[20] សំណើ ។

[21] *ជម្រើសមួយសំណើសុំរបស់ អៀង សារី ស្តីពីការអនុវត្តន៍ការទទួលខុសត្រូវដោយមានកំហិតរបស់ថ្នាក់លើនៅ អ.វ.ត.ក,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារលេខ: D345/3, ERN 00475746-00475757 [*ចាប់ពីនេះតទៅហៅថា* សំណើសុំតាមជម្រើសផ្សេង] ។

[22] *សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់,* សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារលេខ: D345/1, ERN 00452734-00452736 ។

[23] ដីកា, កថាខ័ណ្ឌទី៦-៩ ។

[24] *ដដែលដូចខាងលើ ។*

00508617



សម្រេចដោយអង្គបុរេជំនុំជម្រះថា អ្វីដែល ស.ច.ស បានរកឃើញគឺជាអ្វីដែលបានលើកឡើងមិនត្រឹមត្រូវនៅចំពោះមុខខ្លួន ។ បន្ទាប់ពីបរាជ័យក្នុងការធ្វើឱ្យ ស.ច.ស ជឿថាគេត្រូវការទំព័របន្ថែមដើម្បីលើកឡើងពីបញ្ហាទាំងនេះ ដើមបណ្តឹងឧទ្ធរណ៍ឥឡូវនេះ បានធ្វើមិនដឹងមិនឮយ៉ាងច្បាស់ក្រឡែតចំពោះសេចក្តីបង្គាប់របស់ ស.ច.ស ដែលឱ្យដាក់បញ្ចូលអំណះអំណាងទាំងអស់ស្តីពីប្រធានបទនេះ នៅក្នុងសារណាតែមួយតាមការកំណត់ចំនួន១៥ទំព័រ ។ អង្គបុរេជំនុំជម្រះមិនគួរអនុញ្ញាតឱ្យដើមបណ្តឹងឧទ្ធរណ៍ធ្វើមិនដឹងមិនឮចំពោះសេចក្តីបង្គាប់របស់ ស.ច.ស ទេ តាមរយៈការលើកឡើងពីបញ្ហានានានៅក្នុងបណ្តឹងឧទ្ធរណ៍នេះដែលមិនបានត្រូវអនុញ្ញាតដោយ ស.ច.ស ។

១៦. ជាការបន្ថែម គោលការណ៍ជាសារវ័ន្តស្តីពីទម្លាប់នៃការអនុវត្តន៍គឺថា ភាគីមិនអាចប្តឹងឧទ្ធរណ៍នូវបញ្ហាដែលមិនបានលើកឡើងឱ្យបានច្បាស់លាស់ និងសម្រេចនៅក្នុងសេចក្តីសម្រេចដែលបានតវ៉ាឡើយ ។ ប៉ុន្តែនោះគឺជាអ្វីដែលដើមបណ្តឹងឧទ្ធរណ៍កំពុងតែប៉ុនប៉ងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ។ ទន្ទឹមគ្នានេះដែរ ស.ព សូមស្នើឱ្យ អង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន និងមិនគួរសម្រេចទៅលើបញ្ហាខាងក្រោមនេះទេ: ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងការអនុវត្តរបស់វាចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុង ឬពេលវេលានៃសន្តិភាព; ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងការអនុវត្តរបស់វាចំពោះថ្នាក់លើជាជនស៊ីវិល និងអនុបញ្ជារបស់វា; ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងការអនុវត្តរបស់វាចំពោះមាត្រា៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក; ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងខាងបុព្វហេតុ; និង ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងបទឧក្រិដ្ឋដែលមានចេតនាជាក់លាក់[25] ។

១៧. ប៉ុន្តែ បើសិនអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ស.ព សូមដាក់ការសន្និដ្ឋានដូចតទៅ ។

## ៣. អំណះអំណាងជាសារធាតុ

## អ.វ.ត.ក គឺជាសាលាក្តីអន្តរប្រទេសនិយកម្មពិសេស ហេតុដូច្នេះ តុលាការនេះមិនត្រូវបានរារាំងមិនឱ្យអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិនោះទេ

១៨. ដើមបណ្តឹងឧទ្ធរណ៍តវ៉ាថា អ.វ.ត.ក គឺជា "តុលាការក្នុងស្រុក" មួយ អាស្រ័យហេតុនេះការទទួលខុសត្រូវរបស់អ្នកបញ្ជា (CR) មិនអាចអនុវត្តបានទេនៅក្នុងសំណុំរឿងលេខ០០២ ដោយហេតុថាច្បាប់សហកាលកម្ពុជា ជាពិសេស ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនមានបទប្បញ្ញត្តិណាមួយចែងពីការទទួលខុសត្រូវរបស់អ្នកបញ្ជា[26] ។ បើនិយាយតាមរបៀបផ្សេង ប្រសិនបើ CR មិនអនុវត្តបានដើមបណ្តឹងឧទ្ធរណ៍តវ៉ាពី CR អនុវត្តបានចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ និងមិនអាចអនុវត្ត

[25] សំណើតាមជម្រើសផ្សេង, កថាខ័ណ្ឌទី៤-២២ ។

[26] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី២៩, ៥៧ ។

បានជាបទឧក្រិដ្ឋកម្ពុជាបានទេ តាមមាត្រា៣ថ្មី[27] ។ ស.ព សន្និដ្ឋានថា គោលជំហរទាំងនេះមិនអាចការពារខ្លួនបានទេ ។

១៩. អ.វ.ត.ក មិនមែនជា "តុលាការក្នុងស្រុក" ទេ ។ អង្គបុរេជំនុំជម្រះបានទទួលយកសេចក្តីពិពណ៌នារបស់ ស.ព អំពី អ.វ.ត.ក ថាជា "សាលាក្តីពិសេសដែលមានចរិតលក្ខណៈជាអន្តរជាតិ" ប្រហាក់ប្រហែលគ្នានឹងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")[28] ។

២០. អ.វ.ត.កទទួលថវិកាគាំទ្រពីរដ្ឋបរទេស មានបុគ្គលិកអន្តរជាតិនៅគ្រប់ការិយាល័យទាំងអស់របស់តុលាការ ទទួលបានសិទ្ធិអំណាចជាតិ និងអន្តរជាតិស្មើៗគ្នាទាំងអស់នៅក្នុងការិយាល័យអយ្យការ និងចៅក្រមស៊ើបអង្កេត និងមានភាគតិចជាងរបស់អន្តរជាតិនៅគ្រប់អង្គជំនុំជម្រះទាំងអស់[29] ។ *ក្នុងចំណោមកិច្ចការផ្សេងទៀត* អ.វ.ត.ក គឺជាផលិតផលចេញពីសិទ្ធិសញ្ញាទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ និងអនុវត្តច្បាប់អន្តរជាតិ ។ បើគ្មានធាតុផ្សំទាំងនេះទេ អ.វ.ត.ក ក៏លែងមានដែរ ។ អ.វ.ត.ក ត្រូវបានបង្កើតឡើង ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិ ផ្អែកទៅលើទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាអន្តរជាតិ ចំពោះបុគ្គល ដូចជា CR ជាដើម ដែលត្រូវបានទទួលស្គាល់ជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិ (CIL)[30] ។

២១. *នៅក្នុងការជជែកវែកញែក* ទោះបីជា អ.វ.ត.ក ជាតុលាការក្នុងស្រុកក៏ដោយ ក៏គ្មានឧបសគ្គផ្លូវច្បាប់ចំពោះតុលាការកម្ពុជាក្នុងការអនុវត្តន៍ ទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាអន្តរជាតិលើបុគ្គលចំពោះបទឧក្រិដ្ឋជាតិ និងអន្តរជាតិទេ[31] ។ កម្ពុជា ក្នុងនាមជារដ្ឋអធិបតេយ្យភាពមួយ អាចកំណត់ពីមូលដ្ឋានច្បាប់ដែលខ្លួនចង់កាត់សេចក្តីចំពោះពលរដ្ឋរបស់ខ្លួន ប្រសិនបើមូលដ្ឋាននោះស្របច្បាប់[32] ។ CR ជាផ្នែកនៃ CIL ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងអាចអនុវត្តបានចំពោះបទឧក្រិដ្ឋដែល អ.វ.ត.ក មានយុត្តាធិការទៅលើ ។

---

[27] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី៥៧ ។

[28] *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០១), អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, ឯកសារលេខ: C5/45, ERN 00154284-00154301, កថាខ័ណ្ឌទី១៩ ។

[29] មាត្រា៣, ៥, ៦, ៨, ២១ នៃកិច្ចព្រមព្រៀង អវតក ។ មាត្រា៩ថ្មី, ១៦, ២៣ថ្មី, ៣០, ៤៤ថ្មី នៃច្បាប់ អវតក ។ វិធាន៥.៣, ១១, ១២.គស្ទួន, ២៣.ខ ស្ទួនលើកទីពីរ ។

[30] ស្រដៀងគ្នានឹងតុលាការ ICTY ដែរ, អវតក ត្រូវបានបង្កើតឡើងបន្ទាប់ពីមានការប្រព្រឹត្តិបទឧក្រិដ្ឋដែលអង្គជំនុំជម្រះនេះមានយុត្តាធិការក្នុងកាត់សេចក្តី ដូច្នេះខ្លួនត្រូវកាត់សេចក្តីតែបទឧក្រិដ្ឋណាដែល "ហួសពីមិនសង្ស័យដែលបានក្លាយជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិតែប៉ុណ្ណោះ"។ អគ្គលេខាធិការអង្គការសហប្រជាជាតិ, *របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខ័ណ្ឌទី២ នៃដំណោះស្រាយរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣)*, កថាខណ្ឌទី៣៥ ។

[31] ចែងថា ទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល គឺជាច្បាប់ទម្លាប់អន្តរជាតិនៅពេលបទល្មើសដែលកម្ពុជា ឬប្រទេសជាតិណាមួយ ស្វែងរកដើម្បីធ្វើការវិនិច្ឆ័យទោស ។

[32] ANTONIO CASSESE, ច្បាប់អន្តរជាតិ ៤៩ (ច្បាប់បោះពុម្ពផ្សាយលើកទី២ ឆ្នាំ២០០៥) ។

២២. ក្រោមច្បាប់អន្តរជាតិ គ្មានវិធានណាមួយដែលតម្រូវឲ្យកម្ពុជាត្រូវតែអនុម័តច្បាប់ដែលកំពុងអនុវត្តតែអនុវត្តក្នុងស្រុក ដើម្បីឲ្យច្បាប់ទម្លាប់ CIL អាចអនុវត្តបាននោះទេ[33] ។ តាមពិត លក្ខណៈតែមួយគត់របស់ CIL គឺថាវាអនុវត្តបានស្មើៗគ្នាចំពោះរដ្ឋទាំងអស់ ដោយពុំចាំបាច់មានការយល់ព្រមច្បាស់លាស់ពីគ្រប់ប្រទេសនៃពិភពលោកនេះទេ[34] ។ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង អ.វ.ត.ក[35] និងបានអនុម័តច្បាប់បង្កើត អ.វ.ត.ក[36] ។ ការណ៍នេះអាចឲ្យគេបកស្រាយបានថា ជាការបញ្ជាក់ពីការទទួលយករបស់កម្ពុជាថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល អាចអនុវត្តបាននៅកម្ពុជា[37] ។

២៣. ក្នុងនាមជាសាលាក្តីអន្តរតុលាការពិសេស សំណួរអំពីបញ្ហាថាតើ អ.វ.ត.ក អាចអនុវត្តបានទេ ចំពោះទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលទទួលបានការទទួលស្គាល់ជាអន្តរជាតិ - ក្នុងករណីនេះគឺ CR - ចំពោះឧក្រិដ្ឋកម្មក្នុងស្រុក មកដល់ពេលនេះលែងជាការចាំបាច់ហើយ ។ មាត្រា៣ថ្មី, បទឧក្រិដ្ឋគឺជាបទឧក្រិដ្ឋក្នុងស្រុក នៅក្នុងសម័យកាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយ CR ត្រូវបានដាក់តម្កល់នៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ហើយ CIL កើតមានក្នុងសម័យកាលដូចគ្នា ។ តាមរយៈ និងដោយ អ.វ.ត.ក កម្ពុជាបានសម្រេចចិត្តកាត់សេចក្តីចំពោះបទឧក្រិដ្ឋទាំងនេះ និងបានដាក់បញ្ចូល CR ថាជាមូលដ្ឋានមួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ។

## គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង
## មិនរារាំងចំពោះការប្រើប្រាស់ការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) ទេ

[33] *សូមអាន Regina ទល់នឹង Bow St. Stipendiary Magis.,* [1999] [1999] 1 A.C 147 (H.L) ទំព័រ២៤២-៤៣ (បណ្តឹងឧទ្ធរណ៍យកពីប្រទេសអេស្ពាញ (បង្ហាញនូវការបកស្រាយជាសកល) នៃយុត្តាធិការសម្រាប់រដ្ឋណាមួយ នៅក្នុងការវិនិច្ឆ័យទោសចំពោះអំពើរំលោភលើ *ឋានៈចាប់បង្ខំ* នៃច្បាប់ទម្លាប់អន្តរជាតិ នៅក្នុងរដ្ឋដែលពុំមានច្បាប់ក្នុងស្រុកសម្រាប់ជាការអនុញ្ញាតជាពិសេសក្នុងការវិនិច្ឆ័យទោសដូច្នេះ) ។ *Rt. Hon Lord Hope of Craighead, The Rule of Law Legacy of the House of Lords" Pinochet Juddment,* 43, ច្បាប់អន្តរជាតិ, 45 (2009) ទំព័រទី៤៧-៤៩ ។

[34] *ករណីទាក់ទងនឹងសកម្មភាពយោធា និងយោធាប្រតិព័ទ្ធ នៅក្នុងប្រទេស Nicaragua និងប្រទេសប្រទេសនេះ* (Nicar ទល់នឹង U.S), 1986, I.C.J. 14, 113-14 (មិថុនា ២៧) [*ចាប់ពីនេះតទៅហៅថា* ករណីយោធាប្រតិព័ទ្ធ] ។ MALCOLM NATHAN SHAW, ច្បាប់អន្តរជាតិ លេខ៧០ (ច្បាប់បោះពុម្ពផ្សាយលើកទី៣ ឆ្នាំ២០០៣) ។ Michael Scharf: *The Letter of the Law: វិសាលភាពនៃកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិក្នុងការវិនិច្ឆ័យទោសបទឧក្រិដ្ឋសិទ្ធិមនុស្ស,* 59 LAW & CONTEMP. PROBS. 41, (1996), ទំព័រទី៥២-៥៩ ។

[35] ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា, *លិខិតុបករណ៍ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ,* ១៩ តុលា ២០០៤ ។

[36] ច្បាប់វិសោធនកម្ម ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, នស/រកម/១០០៤/០០៦, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

[37] *សូមអាន* អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា, ២៣ ឧសភា ១៩៦៩, មាត្រា១៨, អាចរកបានតាមវេបសាយ: http://untreaty.un.org/ilc/texts/instruments/english/conventions/1_1_1969.pdf. [*ចាប់ពីនេះតទៅហៅថា* អនុសញ្ញាទីក្រុងវីយែន] ។

២៤. ជនត្រូវចោទ មានសិទ្ធិទទួលបានសវនាការត្រឹមត្រូវយុត្តិធម៌ ។ សិទ្ធិទទួលបានសវនាការដ៏ត្រឹមត្រូវយុត្តិធម៌នេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងបានតម្កល់ដោយផ្ទាល់ និងតាមសេចក្តីយោងនៅក្នុងកិច្ចព្រមព្រៀង, ច្បាប់ និងវិធានផ្ទៃក្នុង អ.វ.ត.ក[38] ។ ក្នុងចំណោមសិទ្ធិទទួលបានសវនាការត្រឹមត្រូវយុត្តិធម៌នេះ ការហាមឃាត់មិនឱ្យមានការអនុវត្តច្បាប់ប្រតិសកម្ម ដែលមានការទាក់ទងគ្នាទៅវិញទៅមកជាមួយនឹងគោលការណ៍នីត្យានុកូលភាព (*គ្មានបទល្មើសបើគ្មានច្បាប់ចែង*) គឺជាគោលការណ៍ជាមូលដ្ឋានមួយដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ចុងចោទនៅអ.វ.ត.ក[39]។ ប៉ុន្តែការអនុវត្តន៍ CR នៅអ.វ.ត.ក មិនរំលោភទៅលើគោលការណ៍នីត្យានុកូលភាពទេ ដោយហេតុថា វាជាផ្នែកនៃច្បាប់ទម្លាប់ CIL ក្នុងសម័យកាលនៃឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

២៥. បណ្តឹងឧទ្ធរណ៍នេះ ពឹងផ្អែកទៅលើការយល់ ឬនិយមន័យមិនត្រឹមត្រូវអំពីច្បាប់ទម្លាប់ CIL ។ គេមានការយល់ខុសជាមូលដ្ឋាន (ឬយ៉ាងហោចណាស់ ជាការងាយពេក) ទៅលើគោលគំនិតនៃច្បាប់ CIL និងពីរបៀបដែលច្បាប់នេះត្រូវបានបង្កើត ។ ដើម្បីឱ្យល្អិតល្អន់ជាងនេះ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ភាគច្រើនបានជជែកវែកញែកថា គេមិនចាំបាច់បំពេញនូវលក្ខខណ្ឌតម្រូវនៃ "ទម្លាប់នៃការអនុវត្តរបស់រដ្ឋត្រូវតែស្របគ្នា" ទេ ពីព្រោះថា គេគ្មានការព្រមព្រៀងគ្នាអំពីបរិមាណ/ចំនួននៃភាពស៊ីសង្វាក់គ្នាដាច់ខាតណាមួយអំពីទម្លាប់នៃការអនុវត្តរបស់រដ្ឋឡើយ ។ តាមការពិត សូម្បីតែទម្លាប់នៃការអនុវត្តរបស់រដ្ឋពីរ គឺជាការគ្រប់គ្រាន់ហើយ[40] ។ ជាងនេះទៀត ភាពមិនស៊ីសង្វាក់គ្នា ឬការបកស្រាយ/ការអនុវត្តន៍ខុសគ្នាលើគោលការណ៍ (ក្នុងករណី CR មានទាក់ទងទៅនឹងបទដ្ឋាន *បំណងឧក្រិដ្ឋ*) មិនបានធ្វើឱ្យតម្លៃរបស់វិធានទេ ប៉ុន្តែនៅក្នុងពាក្យពេចន៍របស់តុលាការកំពូលរបស់សហរដ្ឋអាមេរិក គេអាចពិចារណាថាគ្រាន់តែជា "ការដើរថយក្រោយ"[41] ។ តុលាការយុត្តិធម៌អន្តរជាតិក៏បានសម្រេចថា ទម្លាប់នៃការអនុវត្តន៍របស់រដ្ឋមិនចុះសម្រុងគ្នាជាទូទៅត្រូវបានគេមើលឃើញថា ជាការបំពារបំពានគោលការណ៍នៃច្បាប់ CIL នេះ មិនមែនជាភស្តុតាងប្រឆាំងនឹងអត្ថិភាពរបស់វាទេ[42] ។ ពិតណាស់ ការព្រមព្រៀងគ្នារបស់រដ្ឋមួយ គេមិនចាំបាច់តម្រូវឱ្យមានការអនុវត្តន៍គោលការណ៍ណាមួយនៃច្បាប់ CIL ទេ ជាហេតុធ្វើឱ្យអំណះអំណាងរបស់ដើមបណ្តឹងឧទ្ធរណ៍ដែលថា កម្ពុជាមិនបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមI មុនឆ្នាំ១៩៧៥ គឺមិនពាក់ព័ន្ធគ្នាទេ (យ៉ាងហោចណាស់ និងតាមអ្វីដែល ស.ព បានដឹង គេគ្មានភស្តុតាងដែលថា កម្ពុជា បានជំទាស់ជាបន្តបន្ទាប់ទៅនឹងគោលការណ៍ CR ឬបានបង្ហាញហេតុការណ៍ពីការជំទាស់ណាមួយទាល់តែសោះ) ។

---

[38] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា១៣.១ ។ ច្បាប់ អ.វ.ត.ក, មាត្រា៣៣ថ្មី ។ វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន២១ ។

[39] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ១៦ ធ្នូ ១៩៦៦, មាត្រា១៥ ។

[40] MALCOLM NATHAN SHAW, ច្បាប់អន្តរជាតិ ៦៨-៧៧ (ច្បាប់បោះពុម្ពផ្សាយលើកទី៥ ឆ្នាំ២០០៣) ។ ANTONIO CASSESE, ច្បាប់អន្តរជាតិ ១៥៦-១៦០ (ច្បាប់បោះពុម្ពផ្សាយលើកទី២ ឆ្នាំ២០០៥) ។

[41] *The Paquete Habana*, 175 U.S. 677, 686 (1900) ។

[42] ករណីយោធាប្រតិព័ទ្ធ, កថាខណ្ឌទី១១៣-១៤ ។

២៦. ភាពស្មុគ្រស្មាញគួបផ្សំគ្នានឹងការបង្កើតឡើងនូវច្បាប់ទម្លាប់អន្តរជាតិ (CIL) ក៏មានផលប៉ះពាល់ទៅលើការកំណត់អំពីថា តើគោលការណ៍អំពីនីត្យានុកូលភាពមានផលប៉ះពាល់ទៅលើការអនុវត្តនូវការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) នៅ អវតក ដែរឬទេ? មានការពិចារណាបឋមចំនួនពីរដែលដើមបណ្ដឹងឧទ្ធរណ៍ខកខានមិនបានលើកឡើងនៅក្នុងរឿងនេះ ។ ទី១ គោលការណ៍អំពីនីត្យានុកូលភាពដែលអនុវត្តយ៉ាងតឹងរ៉ឹងនៅក្នុងយុត្តាធិការក្នុងស្រុកនានា មិនត្រូវបានគេយកទៅអនុវត្តដោយមានអានុភាពដូចគ្នានៅក្នុងយុត្តាធិការអន្តរជាតិនានានោះទេ ឬតាមការពិតនៅក្នុងតុលាការអន្តរជាតិជំនាញណាមួយដែលមានលក្ខណៈជាតុលាការអន្តរជាតិ តួយ៉ាងដូចជា អវតក នេះ[43] ។ នៅក្នុងយុត្តាធិការក្នុងស្រុកនានា ច្បាប់ព្រហ្មទណ្ឌទាំងឡាយត្រូវបានអនុម័តដោយអង្គការនីតិបញ្ញត្តិដែលបង្កើតច្បាប់លក្ខន្តិកៈនានា គឺច្បាប់ទម្លាប់អន្តរជាតិ (CIL) ដែលត្រូវបានយកមកប្រើប្រាស់នៅ អវតក ត្រូវបានធ្វើឱ្យប្រសើរថែមទៀតទៅតាមពេលវេលា តាមរយៈសេចក្ដីសម្រេចនានារបស់តុលាការ, ទម្លាប់អនុវត្តន៍របស់រដ្ឋ, កិច្ចព្រមព្រៀងអន្តរជាតិនានា, ទម្លាប់ និងការអត្ថាធិប្បាយពន្យល់[44] ។ ដោយសារមកពីប្រភពផ្សេងៗទាំងនេះហើយទើបច្បាប់ទម្លាប់អន្តរជាតិ (CIL) បានលេចចេញជារូបរាងឡើង[45] ។ ដោយពិចារណាអំពីប្រភពផ្សេងៗដែលចម្រុះគ្នានោះ តុលាការនានាត្រូវបានអនុញ្ញាតឱ្យ "ធ្វើការបកស្រាយ [] និងស្រាយបំភ្លឺ []" លើគោលការណ៍ទាំងនេះ ដើម្បីកំណត់អំពីបញ្ហាខាងអង្គច្បាប់ដោយឡែកណាមួយចំនួន[46] ។

២៧. នៅពេលធ្វើការវាយតម្លៃអំពីគោលការណ៍នីត្យានុកូលភាព តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ("ICTY")[47] និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR")[48]

---

[43] ករណីរឿងក្ដីរបស់ *សហរដ្ឋអាមេរិក ទល់នឹង Alstotter "ករណីរឿងយុត្តិធម៌ "* ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ **នៅក្នុងសវនាការជំនុំជម្រះក្ដី ឧក្រិដ្ឋកម្មជនសង្គ្រាម ចំណូន ៣ណេីក នៅចំពោះមុខតុលាការសិកទីក្រុងនូរ៉ាំប៊ឺហ្គ (Nuremberg)** 974-75 (ឆ្នាំ១៩៩៧) (គឺជាការមិនសមហេតុសមផលទាំងស្រុងក្នុងការស្នើយោបល់ថា វិធាន*ដែលមានឡើងនៅក្រោយអង្គហេតុ* ដូចដែលត្រូវបានស្គាល់ពីបណ្ដារដ្ឋអាស្រ័យធម្មនុញ្ញនានា អាចត្រូវបានគេយកទៅអនុវត្តនៅក្នុងសន្ធិសញ្ញា ទម្លាប់ ឬសេចក្ដីសម្រេចណាមួយរបស់តុលាការអន្តរជាតិណាមួយនៅក្នុងប្រព័ន្ធច្បាប់អង់ហ្គ្លេអាមេរិកាំង ឬពីការទទួលយល់ព្រមជាអន្តរជាតិ បន្ទាប់ពីព្រឹត្តិការណ៍ទាំងនេះមក)។ [ការធ្វើដូចនេះ] គឺមុខជានឹងច្របាច់កច្បាប់នេះឱ្យស្លាប់ តាំងពីពេលទើបនឹងកើត") ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន,...* សំណុំរឿងលេខ IT-96-21-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ វិច្ឆិកា ១៩៩៨, កថាខណ្ឌទី ៤០៤-៤០៥ [*ចាប់ពីនេះតទៅហៅថា* សាលក្រមជំនុំជំរះក្ដីករណីរបស់ *Čelebići*] ។

[44] លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ, 59 Stat. 1005, ចុះថ្ងៃទី២៦ មិថុនា ១៩៤៥, មាត្រា៣៨ ។

[45] *សូមអាន* ANOTONIO CASSESE ដែលមានចំណងជើងថា **ច្បាប់អន្តរជាតិ** ១៧-១៨ [ការបោះពុម្ពផ្សាយលើកទី២ ឆ្នាំ២០០៨] ។ *សូមអាន* MALCOLM NATHAN SHAW ដែលមានចំណងជើងថា **ច្បាប់អន្តរជាតិ** ៧២-៧៤ [ការបោះពុម្ពផ្សាយលើកទី៥ ឆ្នាំ២០០៣] ។

[46] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Aleksovski និងគូកន,...* សំណុំរឿងលេខ IT-95-14/1-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៤ មីនា ២០00, កថាខណ្ឌទី ១២៧ ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Delalić និងគូកន,...* សំណុំរឿងលេខ IT-96-21-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី ១៧៣ [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ *Čelebići*] ។

[47] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Natelitić,* សំណុំរឿងលេខ IT-98-34-A, សាលដីកា, យោបល់ជំទាស់ដាច់ដោយឡែក និងផ្នែកខ្លះៗរបស់ចៅក្រម Schomburg, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣ ឧសភា ២០០៦, កថាខណ្ឌទី ២៨ ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង*

និងតុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប[49] គឺមិនតម្រូវឱ្យច្បាប់ដែលមានបញ្ហានេះមានអត្ថិភាពតាំងពីមុនមកនូវពាក្យពេចន៍ច្បាស់លាស់ និងធាតុផ្សំនានានោះទេ ។ តុលាការទាំងនេះ គ្រាន់តែតម្រូវឱ្យច្បាប់នោះត្រូវបានទទួលស្គាល់នៅក្នុងកំរិតមួយថា អាចព្យាករណ៍ទុកជាមុនបាន និងថាមុខជានាំមកនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាពុំខាន[50]។ ស្របតាមនេះការយកការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) មកអនុវត្តនៅ អវតក គឺមិនបំពានទៅលើគោលការណ៍នីត្យានុកូលភាពនោះទេ បើសិនជាការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) នេះមានចែងស្រាប់ហើយនៅក្នុងច្បាប់អន្តរជាតិនៅក្នុងសម័យកាលពីឆ្នាំ១៩៧៥ ដល់១៩៧៩ ក្នុងទម្រង់មួយគ្រប់គ្រាន់ដែលអាចឱ្យទទួលស្គាល់បាន ដើម្បីបង្ហាញឱ្យឃើញពីទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ។

## ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិ ក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

២៨. ទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) មានអត្ថិភាពនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ (CIL) តាំងពីមុនអម្លុងពេលនៃឆ្នាំ១៩៧៥ ដល់ ១៩៧៩ និងត្រូវបានគេយកមកអនុវត្តសម្រាប់មេដឹកនាំយោធា និងស៊ីវិលនានា តាំងពីមុនខ្មែរក្រហមឡើងកាន់អំណាចម្ល៉េះ។ ការណ៍នេះត្រូវបានបញ្ជាក់ជាភស្តុតាងដោយទម្លាប់អនុវត្តរបស់រដ្ឋក្នុងលក្ខណៈជាទូទៅ, ស្របគ្នា និងយ៉ាងទូលំ

---

*Hadžihasanović*, សំណុំរឿងលេខ IT-01-47-PT, ដីកាសម្រេចលើការតវ៉ាជំទាស់រួមគ្នាទៅនឹងយុត្តាធិការ, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ធ្នូ ២០០២, កថាខណ្ឌទី១៦២-៦៥ [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចលើបញ្ហាយុត្តាធិការករណី *Hadžihasanović*] ។

[48] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន,...* សំណុំរឿងលេខ ICTR-98-44-T, ដីកាសម្រេចលើញត្តិស្នើសុំបឋមដោយមេធាវី Joseph Nzirorera, Edouard Karemera, André Rwamakuba និង Mathieu Ngirumpatse ដែលតវ៉ាជំទាស់អំពីយុត្តាធិការទាក់ទងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ឧសភា ២០០៤, កថាខណ្ឌទី៣៧ ("បើសិនជាគោលការណ៍អាចត្រូវបានបង្ហាញឱ្យឃើញថាត្រូវបានបង្កើតឡើងយ៉ាងដូច្នេះមែន គឺវាមិនមែនជាការជំទាស់ទៅនឹងការអនុវត្តគោលការណ៍ចំពោះសភាពការណ៍ដោយឡែកណាមួយ ដើម្បីនិយាយថា សភាពការណ៍នេះថ្មីនោះទេ បើសិនជាមានភាពសមហេតុសមផលថាការអនុវត្តន៍នេះស្ថិតនៅក្នុងរង្វង់នៃការអនុវត្តគោលការណ៍នោះ ") ។

[49] *ករណីរឿងរបស់ Streletz, Kessler និង Krentz ទល់និង ប្រទេសអាល្លឺម៉ង់*, សាលក្រម, ចុះថ្ងៃទី២២ មីនា ២០០១, ការអនុវត្តន៍លេខ 33044/96, 35532/97, 44801/98 , សវនាការនៃអង្គជំនុំជម្រះខ្មាតធំនៃតុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប, កថាខណ្ឌទី ១០៥ ។

[50] *សូមអាន ឧទាហរណ៍ ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Hadžihasanović*, សំណុំរឿងលេខ IT-01-47-AR72, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំដែលតវ៉ាជំទាស់ផ្នែកយុត្តាធិការទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី១៦ កក្កដា ២០០៣, កថាខណ្ឌទី៣៤ ("[] គោលការណ៍នីត្យានុកូលភាពមានលក្ខខណ្ឌតម្រូវឱ្យ បទល្មើសដែលយកមកចោទប្រកាន់ត្រូវតែមានចែងក្នុងច្បាប់ណាមួយដែលអាចយកមកប្រើបាន និងថា បទល្មើសនោះត្រូវតែអាចឱ្យធ្វើការព្យាករណ៍ទុកជាមុនបានថា ការប្រព្រឹត្តដែលជាបញ្ហានេះអាចនិងត្រូវផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌបាននៅពេលដែលបទល្មើសនោះត្រូវបានចោទថា ត្រូវបានប្រព្រឹត្ត... [] ដូចការព្យាករណ៍ទុកការប្រព្រឹត្តដែលជាញ្ហានេះគឺជាការប្រព្រឹត្តជាក់ស្តែងរបស់ជនជាប់ចោទ។ ជននេះត្រូវតែអាចឱ្យគេវាយតម្លៃបានថា ការប្រព្រឹត្តគឺមានលក្ខណៈជាបទព្រហ្មទណ្ឌ នៅក្នុងន័យដែលអាចឱ្យយល់បានជាទូទៅដោយមិនចាំបាច់យោងទៅលើបញ្ញត្តិជាក់លាក់ណាមួយនោះទេ") [*ចាប់ពីនេះតទៅហៅថា* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើករណីបន្ទាន់បន្ទំ] ។

ទូលាយ ក្នុងការយកមកអនុវត្តនូវការទទួលខុសត្រូវរបស់ថ្នាក់លើធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល នៅក្នុងការជំនុំជំរះក្តីនានាពីបទឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងតុលាការជាតិ និងអន្តរជាតិ ការចងក្រងធ្វើជាក្រមជាតិ និងអន្តរជាតិស្តីពីទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលនេះ ក្នុងបណ្តារដ្ឋជាច្រើននិងនៅក្នុងការប្រកាសជាផ្លូវការណ៍នានា ។ នេះគឺជាការផ្តល់នូវភស្តុតាងដែលគួរឲ្យជឿទុកចិត្តបានអំពីទម្លាប់អនុវត្តរបស់រដ្ឋជាលក្ខណៈ ទូលំទូលាយ និងអំពី *កាតព្វកិច្ចតាមផ្លូវច្បាប់ (opinio juris)* ដែលបង្កើតនូវច្បាប់ទម្លាប់អន្តរជាតិ (CIL) នោះ ។

២៩. ការលើកជាសំអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា មានចំនួនករណីរឿងតិចតួចពេកស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) ដែលមានអត្ថិភាពនៅក្នុងយុត្តាធិការចំនួនតិចតួចប៉ុណ្ណោះ និងថា ហេតុដូចនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) មិនអាចជាផ្នែកនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ(CIL)បានទេ គឺជាការយល់ច្រឡំ ។ ធម្មនុញ្ញរបស់តុលាការទីក្រុងនូរ៉ាំប៊ែហ្គ ច្បាប់លេខ ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ និងយុត្តិសាស្ត្រដែលពាក់ព័ន្ធបានបង្កើតទៅជាអ្វីដែលតាមពាក្យរបស់អ្នកសិក្សាស្រាវជ្រាវនានាផ្នែកច្បាប់អន្តរជាតិហៅថាគឺជា ពេលដែលមានការផ្លាស់ប្តូរភ្លាមៗដ៏ធំមួយ (a “Grotian Moment”) នៅពេលដែលមានការអភិវឌ្ឍន៍ការផ្លាស់ប្តូរណាមួយដែលក្នុងនោះវិធាននិងទ្រឹស្តីថ្មីៗ ស្តីពីច្បាប់ទម្លាប់អន្តរជាតិ (CIL) បានលេចឡើងក្នុងភាពដ៏ឆាប់រហ័សខុសពីធម្មតា និងដែលមានការទទួលយល់ព្រម[51]។ គណៈកម្មការផ្នែកច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ធម្មនុញ្ញរបស់តុលាការទីក្រុងទីក្រុងនូរ៉ាំប៊ែហ្គ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ បានផ្តល់កំណើតដល់គំរូសម្រាប់អន្តរជាតិទាំងមូលអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល[52] ។ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ នៅក្នុងវិធានការណ៍មួយក្នុងចំណោមវិធានការណ៍ដំបូងៗរបស់អង្គការសហប្រជាជាតិដែលទើបបានបង្កើតថ្មី មហាសន្និបាតអង្គការសហប្រជាជាតិបានពោលអះអាងជាឯកច្ឆន្ទអំពីគោលការណ៍ទាំងឡាយដែលមកពីធម្មនុញ្ញនិងសាលក្រមនានារបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ[53] ។

---

[51] សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស, ចុះថ្ងៃទី៣១ ធ្នូ ២០០៨, លេខយោងជើងទំព័រលេខ២៦ ។

[52] សូមអាន*របាយករណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ ស្តីពីការងារសម្រាប់សម័យប្រជុំលើកទីសែសិបប្រាំបីរបស់ខ្លួន ពីថ្ងៃទី៦ ឧសភា ដល់២៦ កក្កដា ឆ្នាំ១៩៩៦,* ឯកសារផ្លូវការនៃមហាសន្និបាត អសប., សម័យប្រជុំលើកទី៥១, លេខបន្ថែមលេខ១០ , ទំព័រ១៩ អាចបើកមើលបាននៅក្នុងគេហទំព័រដែលមានអាសយដ្ឋាន: http: www.un.org/law.ilc/index.htm (ដែលរៀបរាប់អំពីគោលការណ៍ស្តីពីការទទួលខុសត្រូវជាបុគ្គលនិងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនានាក្រោមច្បាប់អន្តជាតិ ដែលត្រូវបានទទួលស្គាល់នៅតុលាការទីក្រុងនូរ៉ាំប៊ឺហ្គ (Nuremburg) ថាជា “មូលដ្ឋានគ្រឹះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ”) និង “កេរ្តិ៍តំណែលដ៏ចិតថេរនៃធម្មនុញ្ញ និងសាលក្រមនានារបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ” ។

[53] ការបញ្ជាក់អះអាងអំពីគោលការណ៍នានានៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ, សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អសប. លេខ 95(I), UN GAOR, 1st Sess., UN Doc A/236 (1946) ចំណុចទី២, ត្រង់ទំព័រ ១១៤៤ អាចបើកមើលបាននៅក្នុងគេហទំព័រដែលមានអាសយដ្ឋាន: http: untreaty.un.org/ilc/texts/instruments/english/ draft%20 articles/7_1_1950.pdf. [*ដែលជាបន្តទៅទៀតនៅក្នុងនេះហៅថា* គោលការណ៍នានារបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ]។ សេចក្តីសម្រេចចិត្តដែលបញ្ជាក់អះអាងពីគោលការណ៍នានារបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គនេះ ក៏បានណែនាំផងដែរដល់គណៈកម្មការច្បាប់អន្តរជាតិរបស់ អសប.

00508624



ជាផលវិបាក ការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) គ្រាន់តែត្រូវបានផ្តល់ត្រឹមតែជាផ្នែកមួយរបស់ច្បាប់ទម្លាប់អន្តរជាតិ (CIL) ប៉ុណ្ណោះ ដោយសារទស្សនាទានជាមូលដ្ឋានផ្សេងទៀតនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលបានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍នានារបស់តុលាការទីក្រុងនូរ៉ំប៊ឺហ្គ ដែល អវតក យកមកប្រើ ។ ទស្សនាទានទាំងនេះរួមមាន: ការទទួលខុសត្រូវចំពោះផែនការរួម, គោលការណ៍ដែលថា គោរពតាមបញ្ជារបស់ថ្នាក់លើមិនអាចលើកយកមកដើម្បីការពារបានទេ, គំនិតដែលថា មេដឹកនាំនានាអាចត្រូវបានចាប់បង្ខំឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិនានាទោះបីជាមានដំណែងផ្លូវការរបស់ខ្លួនក៏ដោយ និងសញ្ញាណដែលថា ចារីត្រូវទទួលខុសត្រូវចំពោះអំពើណាមួយដែលជាឧក្រិដ្ឋកម្មស្ថិតនៅក្រោមច្បាប់អន្តរជាតិ ថ្វីត្បិតតែមានអង្គហេតុថាច្បាប់ក្នុងស្រុកមិនដាក់ទោសចំពោះអំពើនោះក្តី ។ នៅក្នុងអម្លុងពេលនេះ បទដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌមួយ ដែលធ្វើឲ្យឃើញយ៉ាងច្បាស់នៅក្នុងច្បាប់ទម្លាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ ។

៣០. មុនសង្គ្រាមលោកលើកទី២ ការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាបទដ្ឋានមួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ បានស្ថិតនៅក្នុងដំណើរការអភិវឌ្ឍន៍ និងការធ្វើឲ្យកាន់តែប្រសើរឡើងជាបន្តទៅទៀត ។ បទដ្ឋាននេះកើតចេញមកពីគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលត្រូវបានអភិវឌ្ឍន៍ជាបឋមតាមរយៈការប្រកាសជាផ្លូវការណ៍ និងលិខិតបទដ្ឋានគតិយុត្តិនានា នៅក្នុងបណ្តារដ្ឋនានាជាច្រើន[54] ។ ទស្សវិទូជនជាតិហុល្លង់ ឈ្មោះ Hugo Crotius បានកត់ត្រាទុកនូវគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ រួមទាំងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ថ្នាក់លើ នៅក្នុងទសវត្សរ៍ឆ្នាំ១៦០០[55] ។

៣១. គោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានរៀបចំចងក្រងជាក្រមអន្តរជាតិដំបូងគេ ដោយមាត្រា១ នៃបទបញ្ជា ដែលគោរពតាមច្បាប់ និងទម្លាប់នានាស្តីពីសង្គ្រាមលើដីគោក (បទបញ្ជានៃទីក្រុងឡាអេ) ដែលជាឧបសម្ព័ន្ធអនុសញ្ញានៃទីក្រុងឡាអេទី៤ ឆ្នាំ១៩០៧ ដែលបានចែងថា៖ "ច្បាប់នានា សិទ្ធិ និងកាតព្វកិច្ចផ្សេងៗស្តីពីសង្គ្រាម មិនគ្រាន់តែសម្រាប់អនុវត្តន៍ចំពោះ

("ILC") ឲ្យរៀបចំចងក្រងគោលការណ៍ទាំងនេះធ្វើជាក្រមនៅក្នុងក្រមអន្តរជាតិមួយ អំពីបទល្មើសផ្សេងៗដែលប្រឆាំងនឹងសន្តភាពហើយនិងសន្តិសុខរបស់មនុស្សជាតិ។ សេចក្តីព្រាងលើកទី១ របស់ ILC នៃក្រម ក្នុងឆ្នាំ១៩៥៦ បានដាក់បញ្ចូលដោយជាក់លាក់នូវគោលការណ៍ស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ពីបទរៀបចំផែនការ ឬចូលរួមនៅក្នុងផែនការរួម ឬមួយក៏រួមគំនិតគ្នានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ" (មាត្រា២ កថាខណ្ឌទី ១៣.ឈ) ។ *សូមអាន របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ ស្តីពីការងារសម្រាប់សម័យប្រជុំលើកទី៤៨ របស់ខ្លួន ពីថ្ងៃទី៦ ឧសភា ដល់២៦ កក្កដា ឆ្នាំ១៩៩៦,* ឯកសារផ្លូវការនៃមហាសន្និបាត អសប., សម័យប្រជុំលើកទី៥១, លេខបន្ថែមលេខ ១០, ត្រង់ទំព័រ២១, អាចបើកមើលបាននៅក្នុងគេហទំព័រដែលមានអាសយដ្ឋាន: http: www.un.org/law.ilc/index.htm ។

[54] អត្ថបទមុនគេបង្អស់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលត្រូវបានស្រង់ជាកំណត់ហេតុ ចុះកាលបរិច្ឆេទតាំងពីពេលដែលមានការចងក្រងនូវសំណេររបស់ឧត្តមសេនីយជនជាតិចិននានាដែលមានឈ្មោះល្បីៗអស់រយៈពេលជាច្រើនពាន់ឆ្នាំមកហើយ ដែលចាប់ផ្តើមតាំងពីសតវត្សរ៍ទី៥មុនគ្រិស្តសករាជមក ។ អត្ថបទរបស់លោក William H. Parks, ដែលមានចំណងជើងថា *ការទទួលខុសត្រូវរបស់អ្នកបញ្ជា(ថ្នាក់លើ)ចំពោះបទឧក្រិដ្ឋកម្មសង្គ្រាម,* 62 Mil.L Review (ឆ្នាំ១៩៧៣), ទំព័រ៤ [*ចាប់ពីនេះតទៅហៅថា* អត្ថបទរបស់លោក Parks] ។

[55] អត្ថបទរបស់លោក Parks ត្រង់ទំព័រ៤ ។

កងទ័ពប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់ចំពោះកងសេនាជន និងកងអង្គភាពស្ម័គ្រចិត្តនានា ដែលបានបំពេញ នូវលក្ខខណ្ឌដូចតទៅនេះផងដែរ៖ [...] ត្រូវតែបញ្ជាដោយជនណាម្នាក់ដែលជាអ្នកទទួលខុសត្រូវចំពោះអ្នកនៅក្រោមបង្គាប់ទាំងឡាយរបស់ខ្លួន”[56] ។

៣២. ក្រោយចប់សង្គ្រាមលោកលើកទី១ សញ្ញាណស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលដោយសារការខកខានមិនបានចាត់វិធានការណ៍ចាំបាច់ដើម្បីទប់ស្កាត់ ឬបង្ក្រាបអំពើរំលោភបំពានច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ដែលលេចឡើងនៅក្នុងបរិបទអន្តរជាតិ។ តាមពិត គោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានពោលបញ្ជាក់អះអាងនៅក្នុងអនុញ្ញាមួយចំនួន ក្រោយពីសង្គ្រាមលោកលើកទី១ រួមទាំងនៅក្នុងមាត្រា២៦ នៃអនុញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩២៩[57] របស់កាកបាទក្រហម និងអនុសញ្ញាស្តីពីប្រព្រឹត្តកម្មចំពោះជនឈ្លើយសឹក ឆ្នាំ១៩២៩[58] ។

៣៣. ក្នុងឆ្នាំ១៩១៩ “ គណៈកម្មការអន្តរជាតិស្តីពីការទទួលខុសត្រូវនៃអ្នកដែលបង្កើតសង្គ្រាម និងស្តីពីការពង្រឹងការអនុវត្តន៍នូវការផ្តន្ទាទោស” បានផ្តល់អនុសាសន៍ឱ្យបង្កើតតុលាការព្រហ្មទណ្ឌមួយសម្រាប់កាត់ទោស *ក្នុងចំណោមជនដទៃទៀតជាច្រើន* នូវជនទាំងអស់ “ដែលបានបញ្ជា ឬដែលបានដឹង និងដែលមានអំណាចដើម្បីធ្វើអន្តរាគមន៍ តែជៀសវាងមិនព្រមធ្វើការទប់ស្កាត់ ឬចាត់វិធានការណ៍ដើម្បីទប់ស្កាត់ ដើម្បីបញ្ឈប់ ឬដើម្បីបង្ក្រាបការរំលោភច្បាប់ ឬទម្លាប់ស្តីពីសង្គ្រាមនោះទេ”[59] ។ នៅទីបញ្ចប់ តុលាការបែបនេះមិនត្រូវបានបង្កើតឡើងទេ ទោះបីជាមានជនជាច្រើនរូបត្រូវបានគេស្គាល់អត្តសញ្ញាណថា ជាឧក្រិដ្ឋជនសង្គ្រាមក៏ដោយក៏សុទ្ធតែត្រូវបានជំនុំជម្រះក្តីនៅក្នុងតុលាការនានារបស់ប្រទេសអាល្លឺម៉ង់ទាំងអស់ ។ ការជំនុំជម្រះក្តីទាំងនេះ ត្រូវបានធ្វើឡើងនៅទីក្រុងឡៃបហ្សិក(Leipzig) ដែលជាលទ្ធផលគឺមានមន្ត្រីចំនួន១២រូបត្រូវបានគេជំនុំជម្រះ ដែលក្នុងនោះមាន៩រូបត្រូវបានសម្រេចថាមានទោស និងបានបង្កើតអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ នៅក្នុងប្រទេសអាល្លឺម៉ង់[60] ។

---

[56] អនុសញ្ញាទី IV ដែលគោរពតាមច្បាប់និងទម្លាប់នានានៃសង្គ្រាមលើដីគោក និងឧបសម្ព័ន្ធរបស់អនុសញ្ញានេះ៖ បទបញ្ញាផ្សេងៗស្តីពី ច្បាប់និងទម្លាប់នានានៃសង្គ្រាមលើដីគោក ចុះថ្ងៃទី ១៨ តុលា១៩០៧, ឧបសម្ព័ន្ធ នៃមាត្រាទី១ ។

[57] អនុសញ្ញាទីក្រុងហ្សឺណែវស្តីពីការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់អ្នកដែលរងរបួស និងមានជម្ងឺនៃកងទ័ពនៅក្នុងសមរភូមិ, ចុះថ្ងៃទី២៧ កក្កដា ១៩២៩, មាត្រា២៦ ។

[58] អនុសញ្ញាទីក្រុងហ្សឺណែវស្តីប្រព្រឹត្តកម្មចំពោះអ្នកទោសឈ្លើយសឹក,ចុះថ្ងៃទី២៧ មិថុនា ១៩២៩, មាត្រា១៨ ។

[59] គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកដែលបង្កើតឱ្យមានសង្គ្រាម និងស្តីពីការអនុវត្តការផ្តន្ទាទោស - របាយការណ៍ដែលបានដាក់ជូនសន្និសីទបឋមស្តីពីសន្តិភាព, ចុះថ្ងៃទី២៥ មករា ១៩១៩, ដែលត្រូវបានធ្វើការបោះពុម្ពផ្សាយឡើងវិញក្រោមចំណងជើងថាៈ **ការរំលោភបំពានលើច្បាប់ និងទម្លាប់នានាស្តីពីសង្គ្រាម**, ២៤ (ឆ្នាំ១៩១៩) ។

[60] អត្ថបទរបស់លោក Stuart E. Hendin, ដែលមានចំណងជើងថាៈ *ការទទួលខុសត្រូវរបស់អ្នកបញ្ជា និងបញ្ជារបស់ថ្នាក់លើនៅក្នុងសតវត្សរ៍ទី២៩- សតវត្សមួយនៃការវិវឌ្ឍន៍,* ដែលបោះពុម្ពផ្សាយដោយ 10 MURDOCH UNIV. ELEC J. OF LAW, ១ (ឆ្នាំ២០០៣), កថាខណ្ឌទី ២៤ [*ចាប់ពីនេះតទៅហៅថា* អត្ថបទរបស់លោក Herdin] ។

៣៤. បន្ទាប់ពីសង្គ្រាមលោកលើកទី២មក បទដ្ឋានស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ត្រូវបានគេធ្វើឱ្យប្រសើរឡើងច្បាស់លាស់ជាងមុន ហើយយុត្តិសាស្ត្រនៅលើបទដ្ឋាននេះត្រូវបានអភិវឌ្ឍន៍ដោយមានចំនួនកើនឡើងទ្វេរដង ។ មានតុលាការមួយចំនួនត្រូវបានគេបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នានាអំពីបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងៗដែលបានប្រព្រឹត្តនៅក្នុងអឡុងពេលសង្គ្រាម។ ដែលរួមមាន តុលាការសឹកអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) នៅក្នុងប្រទេសជប៉ុន និងតុលាការសឹកអន្តរជាតិ(IMT) នៅក្នុងទីក្រុងនូរ៉ាំប៊ឺហ្គ ប្រទេសអាល្លឺម៉ង់ ។ លើសពីនេះ ការជំនុំជម្រះក្តីយោធាដោយឯករាជ្យជាច្រើនត្រូវបានធ្វើឡើងដែលរួមមានការជំនុំជម្រះក្តីរបស់ Yamashida និង Toyoda ហើយនិង ការជំនុំជម្រះក្តីក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ។

៣៥. នៅក្នុងច្បាប់សម្រាប់បង្កើតតុលាការនានាទាំងនេះ ធម្មនុញ្ញនៃតុលាការសឹកទីក្រុងនូរ៉ាំប៊ឺហ្គ (IMT) ធម្មនុញ្ញនៃតុលាការសឹកចុងបូព៌ា(IMTFE), និងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ មិនបានចែងនូវបញ្ញត្តិជាក់លាក់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ[61] ។ ទោះជាយ៉ាងនេះក្តីក៏ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលមួយដែលត្រូវបានទទួលស្គាល់និងយល់ព្រមនៅក្នុងសវនាការជំនុំជម្រះក្តីនានាហើយក្នុងករណីមួយចំនួនបានប្រើប្រាស់ដោយជោគជ័យនូវទ្រឹស្តីនេះចំពោះថ្នាក់លើទាំងខាងយោធា និងទាំងខាងស៊ីវិល[62] ។ តាមពិត ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នូវមេដឹកនាំជនជាតិជប៉ុនជាច្រើនរូប នៅក្នុងសវនាការជំនុំជម្រះក្តីនៅតុលាការសឹក IMTFE [63] ។

៣៦. នៅក្នុងករណីរឿងរបស់ *Yamashita* គឺជាការទទួលស្គាល់មុនគេបំផុតអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលដោយសារការខកខានរបស់មេបញ្ជាការមួយរូប ក្នុងការអនុវត្តន៍នូវការត្រួតពិនិត្យទៅលើអ្នកក្រោមបង្គាប់របស់ខ្លួន ។ ករណីនេះ ត្រូវបានធ្វើការជំនុំជម្រះដោយគណៈកម្មការយោធាមួយរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសហ្វីលីពីន ក្នុងពេលភ្លាមៗបន្ទាប់ពីចប់សង្គ្រាមលោកលើកទីពីរ[64] ។ ទោះបីជាការត្រូវបានកាត់ឱ្យជាប់ទោសរបស់ Yamashita និងការអនុវត្ត

---

[61] អត្ថបទរបស់លោក Herdin ត្រង់កថាខណ្ឌទី៥២ ។

[62] ករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង* *Friedrich Flick និងគូកន,* ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ **នៅក្នុងសវនាការជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មជនសង្គ្រាមសំខាន់ៗ ចំនួន៦លើក នៅចំពោះមុខតុលាការសឹកអន្តរជាតិ,** 1192,94-95 (ឆ្នាំ១៩៤៧) ។ សាលក្រមជំនុំជម្រះក្តីករណីរឿងរបស់ *Čelebići*, កថាខណ្ឌ៣៥៩, អត្ថបទរបស់លើក Herdin, ត្រង់កថាខណ្ឌទី៥២, ១១០ ។

[63] តុលាការសឹកសម្រាប់ចុងបូព៌ា, សាលក្រម, ឧបសម្ព័ន្ធទី៦ ត្រង់កថាខណ្ឌទី៥៩-៦០ (ចុះថ្ងៃទី១ វិច្ឆិកា ១៩៤៨) ។

[64] ករណីរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Tomoyuki Yamashita,* គណៈកម្មការយោធាដែលត្រូវបានតែងតាំងដោយកថាខណ្ឌទី២៤, ដីកាសម្រេចពិសេសលេខ ១១០, ទីបញ្ជាការយោធានៃសហរដ្ឋអាមេរិក, តំបន់ប៉ាស៊ីហ្វិកខាងលិច, ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ នៅក្នុងរបាយការណ៍អំពីច្បាប់លើកទី៤ ស្តីពីសវនាការនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មជនសង្គ្រាម, ១ (ថ្ងៃទី៨ តុលា ១៩៤៥ ដល់ថ្ងៃទី ៧ ធ្នូ ១៩៤៥) ។

ជាបន្ទាប់មកទៀតដែលនាំឱ្យមានភាពចម្រូងចម្រាស់យ៉ាងសំបើមហើយដែលត្រូវទទួលការរិះទៀន អំពីការប្រើប្រាស់នូវ "យុត្តិធម៌របស់អ្នកឈ្នះ"[65] នោះក្តីក៏មិនបានធ្វើឱ្យលែងមានភាពស្របច្បាប់ ឬម្យ៉ាងទៀត ក៏មិនធ្វើឱ្យតម្លៃជាករណីយុត្តិសាស្ត្រនៃសាលក្រមលែងមានសារៈសំខាន់នោះដែរ ។ ការត្រូវកាត់ឱ្យជាប់ទោសរបស់ Yamashita ត្រូវបានគេលើកមកយោងនិងពឹងផ្អែកនៅក្នុងសវនាការជំនុំជម្រះក្តីជាបន្តបន្ទាប់មកទៀតដែលលេចចេញមកពីសង្គ្រាមលោកលើកទីពីរ ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) ។ ដូចដែលអ្នកធ្វើអត្ថាធិប្បាយម្នាក់បានធ្វើការកត់សំគាល់ថា៖

> តម្លៃតាមការសិក្សាទៅលើសវនាការជំនុំជម្រះក្តីនៃករណីរបស់ Yamashita មិនស្ថិតនៅលើការដែលមានការថ្លែងអង្គហេតុមិនត្រឹមត្រូវជាញឹកញាប់ ឬនៅលើទ្រឹស្តីច្បាប់អំពីការទទួលខុសត្រូវម៉ឺងម៉ាត់ដែលគោលការណ៍នេះបានប្រកាន់យកនោះទេ (តែមិនបានធ្វើទេ) ប៉ុន្តែគឺវាស្ថិតនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់បានធ្វើឡើងជាក់ស្តែង ។ Yamashita បានទទួលស្គាល់អំពីអត្ថិភាពនៃករណីកិច្ចជាវិជ្ជមានពីសំណាក់មេបញ្ជាការម្នាក់ៗ ដែលត្រូវចាត់វិធានការណ៍សមស្រប និងក្នុងរង្វង់សិទ្ធិអំណាចរបស់ខ្លួន តាមព្រំដែនដែលច្បាប់សង្គ្រាមបានកំណត់សម្រាប់គ្រាមានសង្គ្រាម ជាពិសេស ការអនុវត្តនូវការត្រួតពិនិត្យទៅលើកូនចៅក្រោមបង្គាប់របស់ខ្លួន ។ សេចក្តីសន្និដ្ឋាននេះបានបង្ហាញសក្ខីកម្មឱ្យឃើញថា មេបញ្ជាការដែលមិនយកចិត្តទុកដាក់ចំពោះភារកិច្ចរបស់ខ្លួន គឺបានប្រព្រឹត្តល្មើសនឹងច្បាប់សង្គ្រាម។ ហើយសេចក្តីសន្និដ្ឋាននេះបានពោលអះអាងអំពី *ច្បាប់កំពូល (summum jus)* ដែលដាក់មេបញ្ជាការដែលប្រព្រឹត្តល្មើសឱ្យទទួលរងនូវការជំនុំជម្រះក្តីដោយតុលាការណាមួយដែលត្រូវបានបង្កើតឡើងត្រឹមត្រូវនៃរដ្ឋមួយផ្សេងទៀត ក្រៅពីរដ្ឋដែលជារបស់មេបញ្ជាការនោះ[66] ។

៣៧. បន្ទាប់ពី *Yamashita* តុលាការសឹករបស់អូស្ត្រាលីនិងសហរដ្ឋអាមេរិកមួយដែលបើកធ្វើសវនាការនៅទីក្រុងតូក្យូបានធ្វើការកែលំអបទដ្ឋានស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើបន្ថែមទៀត នៅក្នុងករណីរឿងក្តីរបស់ *Toyoda*[67] ។ នៅក្នុងករណីរឿងរបស់ *Toyoda* តុលាការបានបញ្ជាក់អំពី Toyoda ត្រូវមានទោស ហើយបន្ទាប់ពីពិនិត្យឡើងវិញនូវករណីយុត្តិសាស្ត្រដែលពាក់ព័ន្ធបរិយាយលំអិតថែមទៀតអំពីធាតុផ្សំនានាចាំបាច់ ដើម្បីបង្ហាញសក្ខីកម្មឱ្យឃើញពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលនៅក្រោមទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ។

៣៨. តុលាការសឹកIMTFE នៅទីក្រុងតូក្យូបាននាំខ្លួនមកកាត់ទោសនូវមន្ត្រីយោធា និងស៊ីវិលជនជាតិជប៉ុនចំនួន២៨នាក់ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព, ឧក្រិដ្ឋកម្មសង្គ្រាម, និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[68] ។ ធម្មនុញ្ញ IMTFE មិនមានចែងនូវបញ្ញត្តិណាមួយច្បាស់លាស់ដែលនិយាយអំពីការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ។ ប៉ុន្តែ បទចោទទី៥៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

---

65 *សូមអាន* អត្ថបទរបស់លោក Jenny Martinez ដែលមានចំណងជើងថា *ការស្វែងយល់អំពីបំណងទុច្ចរិតនៅក្នុងការទទួលខុសត្រូវរបស់អ្នកបញ្ជា,* ដែលបោះផ្សាយនៅក្នុង 5 J. Int'l Crim. Just, 638 (ឆ្នាំ២០០៧) , ទំព័រ ៦៣៨-៤៩ ។

66 អត្ថបទរបស់លោក Parks, ត្រង់ទំព័រ៣៧ ។

67 *ដដែលដូចខាងលើ,* ត្រង់ទំព័រ៧២ ។

68 តុលាការសឹកសម្រាប់ចុងបូព៌ា, សាលក្រម, ឧបសម្ព័ន្ធទី៦ ត្រង់កថាខណ្ឌទី៥-៦ (ចុះថ្ងៃទី១ វិច្ឆិកា ១៩៤៨) ។

ដែលបានលើកឡើងពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គល តាមវិធីការទទួលខុសត្រូវរបស់ថ្នាក់លើ[69] ។ ជាសំខាន់ បន្ថែមពីលើមេបញ្ជាការយោធានានា តុលាការសឹក IMTFE បានក្លាយខ្លួនទៅជាតុលាការដំបូងគេបង្អស់ ដែលពង្រីកនូវទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ (CR) ទៅដល់ថ្នាក់លើនានាខាងស៊ីវិលទៀត[70] ។

៣៩. ចំណែកឯតុលាការទីក្រុងនូរ៉ាំប៊ឺហ្គវិញ បានជំនុំជម្រះក្តីសមាជិកជាន់ខ្ពស់បំផុតរបស់របបណាហ្ស៊ី ដែលនៅរស់ចំនួនម្ភៃពីររូប[71] ច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ត្រូវបានប្រកាសឱ្យប្រើរួមគ្នាដោយប្រទេសមហាអំណាចខាងសម្ព័ន្ធមិត្ត សម្រាប់គ្រប់គ្រងសវនាការជំនុំជម្រះក្តីលើជនសង្ស័យថាជាឧក្រិដ្ឋជនសង្គ្រាមជនជាតិអាល្លឺម៉ង់ថ្នាក់បន្ទាប់ សម្រាប់ពេលក្រោយៗទៀតដោយតុលាការសឹករបស់សហរដ្ឋអាមេរិក ប្រទេសអង់គ្លេស កាណាដា និងអូស្ត្រាលី ក៏ដូចជាតុលាការអាល្លឺម៉ង់នានានៅលើទឹកដីដែលបរទេសត្រួតត្រានៃប្រទេសអាល្លឺម៉ង់។ ស្ថិតនៅក្រោមអំណាចនៃច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យតុលាការនានាត្រូវតែអនុវត្តតាមធម្មនុញ្ញ និងយុត្តិសាស្ត្ររបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ[72]។ ដូចនេះ ករណីយុត្តិសាស្ត្រ ដែលមកពីតុលាការទាំងនោះត្រូវបានគេយល់ឃើញថា គឺជាការបកស្រាយទៅលើធម្មនុញ្ញ និងសាលក្រមរបស់តុលាការទីក្រុងនូរ៉ាំប៊ឺហ្គ និងជាការឆ្លុះបញ្ចាំងអំពីច្បាប់ទម្លាប់អន្តរជាតិ[73] ។

៤០. ការធ្វើវិភាគមួយទៅលើករណីរឿងក្តីនានាជាច្រើន ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ គាំទ្រសេចក្តីសន្និដ្ឋានដែលថា ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានគេយកមកប្រើធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលសម្រាប់ថ្នាក់លើទាំងយោធា និងស៊ីវិលនៅក្នុងតុលាការនានា[74] ។ ឧទាហរណ៍ដូចជា *ករណីរឿងចាប់ចំណាប់ខ្មាំង* ដែលមន្ត្រីជាន់ខ្ពស់អាល្លឺម៉ង់ត្រូវបានសម្រេចថាមានទោសដែលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ក្រោមទ្រឹស្តីការទទួលខុត្រូវរបស់

---

[69] *ដដែលដូចខាងលើ*, ឧបសម្ព័ន្ធទី៦, បទចោទទី៥៥, ត្រង់កថាខណ្ឌទី៥៩-៦០ ។

[70] អត្ថបទរបស់លោក Greg R. Vetter, *ការទទួលខុសត្រូវរបស់អ្នកបញ្ជានៃថ្នាក់លើទាំងឡាយដែលមិនមែនជាយោធា នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)*, ដែលបោះពុម្ពផ្សាយនៅក្នុង 25 Yale J. INT'L L. 89 (ក្នុងឆ្នាំ២០០០), ទំព័រ១០៣-០៩ ។

[71] *សូមអាន* ធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិ ដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយកិច្ចព្រមព្រៀងក្នុងការកាត់សេចក្តី និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃបក្សសម្ពន្ធយោធានៃទ្វីបអឺរ៉ុប, ចុះថ្ងៃទី៨ សីហា ១៩៤៥, មាត្រា១, ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញនៅក្នុង ទំព័រ១ នៃ **សវនាការជំនុំជម្រះក្តីនៃឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការសឹកអន្តរជាតិ** (ឆ្នាំ១៩៤៧) ។

[72] គេហទំព័រនៃបណ្ណាល័យរបស់ព្រឹទ្ធសភា, ដែលមានចំណងជើងថា *ច្បាប់លេខ១០នៃក្រុមប្រឹក្សាត្រួតពិនិត្យ* ចុះថ្ងៃទី២០ ធ្នូ ១៩៤៥, *ដែលអាចបើកមើលបានតាមអាសយដ្ឋានៈ* http:\www.loc.gov./rr/frd/Military_Law/ Enactment/01LAW09.pdf ។

[73] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Kupreskić*,... សំណុំរឿងលេខ IT-95-16-A,សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៤ មករា ២០០០, កថាខណ្ឌទី៥៤១ ។

[74] អត្ថបទរបស់លោក Hendin, ត្រង់កថាខណ្ឌទី ៥២, ៨៦-៨៨ ។

ថ្នាក់លើចំពោះបទឃាតកម្ម បណ្តេញចេញ និងលួចប្លន់លើជនស៊ីវិលចំនួនរាប់ពាន់នាក់[75] ។ *ករណីរឿងមេបញ្ជាការជាន់ខ្ពស់* បានសម្រេចឱ្យឧត្តមសេនីយមេបញ្ជាការនៃក្រុមកងទ័ពអាល្លឺម៉ង់ភាគខាងជើងមួយរូប និងអ្នកផ្សេងៗទៀត មានទោសពីការប្រព្រឹត្តបទឧក្រិដ្ឋកម្មសង្គ្រាមក្រោមទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើដោយអនុវត្តបញ្ជាដោយខុសច្បាប់ ដោយលើកយកមាត្រា២.(២)នៃ ច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យមកសំអាង[76] ។ ស្រដៀងគ្នានេះដែរ នៅក្នុង*ករណីរឿងក្តីវេជ្ជសាស្ត្រ* បានបញ្ជាក់អះអាងឡើងវិញ អំពីគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដើម្បីទប់ស្កាត់ចំពោះអំពើដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួនដែលរំលោភលើច្បាប់សង្គ្រាម[77] ។

៤១. យុត្តិសាស្ត្រក្រោយពេលសង្គ្រាមលោកលើកទីពីរ បានទទួលការរិះទៀនថា មិនមានភាពរលូនជាពិសេសទាក់ទងអំពីស្ថានភាពនៃបញ្ញាស្មារតីដែលលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលនៅក្រោមទ្រឹស្តីនៃការទទួលខុត្រូវរបស់ថ្នាក់លើ។ វាប្រាកដណាស់ថា បទដ្ឋានស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ និងធាតុផ្សំផ្សេងៗ ស្ថិតនៅក្នុងដំណើរការកែលំអឱ្យប្រសើរឡើងថែមទៀត នៅក្នុងអម្លុងពេលនៃយុត្តិសាស្ត្រក្រោយពីសង្គ្រាមលោកលើកទីពីរ។ ទោះបីជាយ៉ាងណាក្តី ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលដែលត្រូវបានគេយកមកប្រើប្រាស់យ៉ាងរលូន ។ យុត្តិសាស្ត្របានច្រានចោលក្នុងលក្ខណៈស៊ីសង្វាក់គ្នានូវទម្រង់នៃការទទួលខុសត្រូវណាមួយដែលរឹតត្បិតជាងនេះ ដែលនឹងត្រូវយកទៅអនុវត្តសម្រាប់តែថ្នាក់លើទាំងឡាយណា ដែលបានចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលធ្ងន់ធ្ងរតែប៉ុណ្ណោះ។ ជាលទ្ធផល តម្លៃជាយុត្តិសាស្ត្រនៃយុត្តិសាស្ត្រនេះ ស្ថិតនៅជាសំខាន់ដដែល៖ ករណីរឿងក្តីទាំងនេះ បង្ហាញឱ្យឃើញពីការយល់ព្រមទទួលយកការទទួលខុសត្រូវរបស់ថ្នាក់លើធ្វើជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលបានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នៅក្នុងច្បាប់ទម្លាប់អន្តរជាតិ ដែលពេលក្រោយមកទៀតត្រូវបានរៀបចំចងក្រងទៅជាក្រមទាំងនៅក្នុងស្រុក ទាំងនៅអន្តរជាតិ ។

[75] ករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង Wilhelm List, និងគូកន "ករណីរឿងចាប់ពង្រត់ "* ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ **នៅក្នុងសវនាការជំនុំជម្រះក្តី ឧក្រិដ្ឋកម្មជនសង្គ្រាម ចំណួន១១លើក នៅចំពោះមុខតុលាការសឹកទីក្រុងនួរ៉ំប៊ឺហ្គ (Nuremberg) ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ**, ១២៧១-៧៤ (ឆ្នាំ១៩៩៧) ។

[76] ករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង Wilhelm von Leeb, និងគូកន "ករណីរឿងមេបញ្ជាការជាន់ខ្ពស់ "* ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ **នៅក្នុងសវនាការជំនុំជម្រះក្តីឧក្រិដ្ឋកម្មជនសង្គ្រាម ចំនួន១១-១២លើកនៅចំពោះមុខតុលាការសឹកទីក្រុងនួរ៉ំប៊ឺហ្គ (Nuremberg) ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ**, ៥០៧-១០ (ឆ្នាំ១៩៩៧) ។

[77] ករណីរឿងក្តីរបស់ *សហរដ្ឋអាមេរិក ទល់នឹង Karl Brand និងគូកន "ករណីរឿងផ្នែកវេជ្ជសាស្ត្រ "* ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញ **នៅក្នុងសវនាការជំនុំជម្រះក្តី ឧក្រិដ្ឋកម្មជនសង្គ្រាម ចំណួន២លើក នៅចំពោះមុខតុលាការសឹកទីក្រុងនួរ៉ំប៊ឺហ្គ (Nuremberg) ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ**, ២១២ (ឆ្នាំ១៩៩៧) ។

៤២. ការយល់ព្រមទទួលយកយ៉ាងទូលំទូលាយនូវការទទួលខុសត្រូវរបស់ថ្នាក់លើ ធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលក៏បង្ហាញឱ្យឃើញយ៉ាងច្បាស់ផងដែរ អំពីការរៀបចំចងក្រងឱ្យទៅជាក្រមក្នុងស្រុក ដែលបានកើតមានឡើងនៅក្នុងពេលពាក់កណ្ដាលនៃសង្គ្រាមលោកលើកទីពីរ ។ ប្រទេសបារាំងបានអនុម័តនូវបទបញ្ញត្តិមួយ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៤៤ ដើម្បីអនុវត្តនូវបទដ្ឋានស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលបានចែងនៅក្នុងមាត្រា៤ នៃបទបញ្ញត្តិទី១៥ របស់ខ្លួន។ ជាការគួរឱ្យកត់សំគាល់ បទបញ្ញាមួយ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៤៤ ត្រូវបានបង្កើតឡើងសម្រាប់ជំនុំជម្រះក្ដីករណីរឿងឧក្រិដ្ឋកម្មសង្គ្រាម ដែលបានប្រព្រឹត្តនៅក្នុងវង្វង់ទឹកដីនៃប្រទេសបារាំង ឬប្រទេសអាណានិគមរបស់ខ្លួន ដែលក្នុងពេលនោះរួមមាន ប្រទេសកម្ពុជាដែរ[78] ។ ប្រទេសចិនក៏បានអនុម័តច្បាប់មួយចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៦ របស់ចិនផងដែរ "សម្រាប់គ្រប់គ្រងការជំនុំជម្រះក្ដីឧក្រិដ្ឋជនសង្គ្រាមនានា" បន្ទាប់ពីព្រឹត្តិការណ៍នៃសង្គ្រាមលោកលើកទី២ ដែលត្រូវបានគេបង្កើតឡើងសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើសម្រាប់ការខកខានមិនបានទប់ស្កាត់កូនចៅក្រោមបង្គាប់របស់ខ្លួន ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ដូចមានចែងនៅក្នុងមាត្រា៩ [79] ។

៤៣. ប្រទេសលុចហ្សំបួរ បានអនុម័តនូវបទបញ្ញត្តិមួយ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៤៧ ស្ដីពីការលប់បំបាត់ចោលនូវឧក្រិដ្ឋកម្មសង្គ្រាម រួមបញ្ចូលទាំងទ្រឹស្ដីស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើផងដែរ នៅក្នុងមាត្រា៣ [80] ។ ក្នុងឆ្នាំ១៩៤៧ ប្រទេសហុលឡង់ បានដាក់ចូលបន្ថែមនូវមាត្រាពិសេសមួយទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើទៅក្នុងក្រិត្យច្បាប់ព្រហ្មទណ្ឌវិសាមញ្ញរបស់ខ្លួន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៤៣ ត្រង់មាត្រា២៧.(ក).៣[81] ។ ប្រទេសអង់គ្លេសបានអនុម័តច្បាប់មួយស្ដីពីឧក្រិដ្ឋកម្មសង្គ្រាម និងការទទួលខុត្រូវរបស់អ្នកសមគំនិត នៅក្នុងមាត្រា ៨.២ នៅក្នុង រាជបញ្ញានៃប្រទេសអង់គ្លេស (the British Royal warrant) ។ វិធាននេះក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងច្បាប់របស់ប្រទេសកាណាដា ក៏ប៉ុន្តែប្រទេសកាណាដា បានដើរមួយជំហ៊ានលើសពីនេះទៀត ហើយបានដាក់ការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ដោយកូនចៅក្រោមបង្គាប់របស់មេបញ្ជាការមួយរូប[82] ។ គោលការណ៍ស្ដីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល តាមវិធីទទួលខុសត្រូវរបស់ថ្នាក់លើ ក៏ត្រូវបានទទួលស្គាល់នៅក្នុងកូនសៀវភៅវិធីណែនាំជាច្រើនរបស់យោធា ក្រោយពីសង្គ្រាមលោកលើកទីពីរផងដែរ ដែលរួមមានកូន

[78] អត្ថបទរបស់លោក Parks, ត្រង់ទំព័រ៦ ។

[79] *ដដែលដូចខាងលើ*, ត្រង់ទំព័រ១៩ ។

[80] របាយការណ៍ស្ដីពីច្បាប់ លើកទី៤ អំពីសវនាការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម, ៨៧ (គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អសប. ទីក្រុងឡុងដ៍, ឆ្នាំ១៩៤៩), ទំព័រ ៨៧ ។

[81] *ដដែលដូចខាងលើ*, ត្រង់ទំព័រ៨៨ ។

[82] *ដដែលដូចខាងលើ*, ទំព័រទី៨៨ ។

សៀវភៅវិធីណែនាំសម្រាប់ការចុះមូលដ្ឋានរបស់យោធាសហរដ្ឋអាមេរិកឆ្នាំ១៩៥៦[83] កូនសៀវភៅវិធីណែនាំអំពីច្បាប់យោធារបស់ប្រទេសអង់គ្លេសឆ្នាំ១៩៥៨[84] ។

៤៤. នៅក្នុងឆ្នាំ១៩៧៧ ទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានរៀបចំចងក្រងជាផ្លូវការ ទៅជាក្រមក្នុងច្បាប់អន្តរជាតិនៅក្នុងពិធីសារបន្ថែមទី១ ថែមពីលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[85]។ ក៏ប៉ុន្តែ បទដ្ឋានស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើដែលត្រូវបានចងក្រងទៅជាក្រមនេះ មិនបានបង្កើតជាច្បាប់ថ្មី ឬទម្រង់ថ្មីណាមួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលទេ ប៉ុន្តែក្រមនេះគ្រាន់តែធ្វើឱ្យបានស្រប និងឆ្លុះបញ្ចាំងពីបទដ្ឋានដែលបានគោរពតាមការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមាននៅក្នុងច្បាប់អន្តរជាតិស្រាប់រួចមកហើយតែប៉ុណ្ណោះ[86] ។ មានប្រតិភូជាច្រើនបានសំដែងមតិថា ពិធីសារបន្ថែមទី១នេះ គ្រាន់តែរៀបចំចងក្រងទៅជាក្រមនូវគោលការណ៍នានាស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើដែលមានស្រាប់នៅក្នុងច្បាប់ទម្លាប់អន្តរជាតិ (CIL) តែប៉ុណ្ណោះ[87] ។ ទោះជាយ៉ាងណាក្តីក៏អាចឱ្យកត់សំគាល់បានថា វាគឺជាកិច្ចព្រមព្រៀងអន្តរជាតិលើកទី១ ដើម្បីទទួលស្គាល់ឱ្យបានច្បាស់លាស់ចំពោះការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលចំពោះការខកខានរបស់ថ្នាក់លើ នៅក្នុងការទប់ស្កាត់កូនចៅក្រោមបង្គាប់របស់ខ្លួន កុំឱ្យប្រព្រឹត្តនូវអំពើរំលោភបំពានផ្សេងៗទៅលើច្បាប់មនុស្សធម៌អន្តរជាតិ[88] ។

៤៥. នៅមុនពេលរៀបចំបង្កើតតុលាការ ICTY ក្នុងឆ្នាំ១៩៩៣ គ្មានស្ថាប័នតុលាការអន្តរជាតិណាបានអនុវត្តទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើទេ ចាប់តាំងពីករណីរឿងក្តីនានាក្រោយពីសង្គ្រាមលោកលើកទី២មក[89]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងតុលាការ ICTY

---

83 អត្ថបទរបស់លោក Parks, ត្រង់ទំព័រ១៩ ។

84 នាយកដ្ឋានយោធានៃសហរដ្ឋអាមេរិក, *កូនសៀវភៅក្បួនណែនាំសម្រាប់តាមមូលដ្ឋាន,* ២៧-១០: *ច្បាប់ស្តីពីការធ្វើសង្គ្រាមលើដីគោក,* ឆ្នាំ១៩៥៦, កថាខណ្ឌទី៥០១ ។

85 អត្ថបទរបស់លោក Christopher Greenwood, *ការទទួលខុសត្រូវរបស់ថ្នាក់លើ និងដីកាសម្រេចលើករណីរឿងរបស់ Hadžihasanović,* ដែលបោះផ្សាយនៅក្នុង 2 J. INT'L CRIM. JUST., ៥៩៨ (ឆ្នាំ២០០៤), ទំព័រ៦០៤, លេខយោងជើងទំព័រលេខ២០, (ដែលលើកសំអាងផ្អែកលើផ្នែកទី៣ នៃកូនសៀវភៅក្បួនណែនាំអនុវត្តស្តីពីច្បាប់យោធា) ។

86 ពិធីសារបន្ថែមលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ សីហា ១៩៤៩, និងដែលទាក់ទងទៅនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិនានា (ពិធីសារទី១), ដែលបោះផ្សាយនៅក្នុង 1125 U .N.T.S 3, ចុះថ្ងៃទី៨ មិថុនា ១៩៧៧, មាត្រា៨៦.២ ។

87 កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៧ ដំបូងគេ *ស្តីពីការពិនិត្យពិចារណាលើពង្រាងពិធីសារទី១ និងទី២, (CDDH/I),* **នៅក្នុងកំណត់ហេតុជាផ្លូវការណ៍លើកទី៩ នៃសន្និសីទការទូត ស្តីពីការបញ្ជាក់អះអាងជាថ្មីឡើងវិញ និងការអភិវឌ្ឍន៍នូវច្បាប់មនុស្សធម៌អន្តរជាតិសម្រាប់អនុវត្តនៅក្នុងករណីជម្លោះប្រដាប់អាវុធនានា,** ៣៩៩ (ឆ្នាំ១៩៧៤-១៩៧៧) ។

88 ពិធីសារបន្ថែមលើកទី១ *ចូលជាធរមាននៅថ្ងៃទី៧ ធ្នូ ១៩៧៨,* (កម្ពុជាផ្តល់សច្ចាប័ននៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៨) ។

89 *ប៉ុន្តែសូមអានផងដែរនូវ* អត្ថបទរបស់លោក L.C. Green, ដែលមានចំណងជើងថា *ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់មនុស្សធម៌ព្រហ្មទណ្ឌអន្តរជាតិ,* ដែលបោះផ្សាយនៅក្នុង 5, TRANSNAT'L & CONTEMP. PROBS, ៣១៩ (ឆ្នាំ១៩៩៥), ទំព័រ៣៥៦-៥៩, ដែលដកស្រង់សំដីពីក្នុងករណីរឿងរបស់ *អគ្គរដ្ឋអាជ្ញានៃប្រទេសអ៊ីស្រាអែល ទល់នឹង Eichmann* (តុលាការកំពូលនៃប្រទេសអ៊ីស្រាអែល ឆ្នាំ១៩៦២) (ដែលពិភាក្សាស្តីពីទស្សនាទានអំពីច្បាប់ ដែលស្រដៀងគ្នានឹងការទទួលខុសត្រូវរបស់ថ្នាក់លើដែរ) ។

បានសម្រេចថា ការមិនមានការអនុវត្តនេះ គឺវាមិនមានផលប៉ះពាល់ចំពោះការស្ថិតនៅជាធរមានរបស់ទ្រឹស្តីក្នុងនាមជាបទដ្ឋានមួយនៃច្បាប់ទម្លាប់អន្តរជាតិនោះទេ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះនេះបានសម្រេចថា បើសិនជាច្បាប់មួយស្តីពីកាតព្វកិច្ចតាមផ្លូវច្បាប់ មានអត្ថិភាពនោះ "អាចមិនបាច់សង្ស័យទេថា ទស្សនទានអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលរបស់ថ្នាក់លើចំពោះការខកខានក្នុងការចាត់វិធានការណ៍បច្ចុប្បន្ននេះ ត្រូវបានដាក់បញ្ចូលយ៉ាងស៊ីបទៅក្នុងរង្វង់ច្បាប់មនុស្សធម៌អន្តរជាតិ"[90] ។ ទោះបីជាមានភាពមិនតគ្នាដូចនេះនៅក្នុងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅតាមតុលាការអន្តរជាតិនានាក្តី ក៏ច្បាស់ណាស់ថាគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើបានមានអត្ថិភាពរួចទៅហើយ ក្នុងនាមជានិយាមមួយនៃច្បាប់អន្តរជាតិតាំងពីមុនអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ ។ អាស្រ័យហេតុនេះ ទម្លាប់អនុវត្តរបស់រដ្ឋក្នុងការប្រើប្រាស់ទ្រឹស្តីនេះក្នុងភាពរលូនគ្នា និងយ៉ាងទូលំទូលាយនៅតាមតុលាការជាតិ និងអន្តរជាតិនានា និងនៅក្នុងលិខិតុបករណ៍អន្តរជាតិ ហើយនិងឋានៈនៃ*កាតព្វកិច្ចតាមផ្លូវច្បាប់ (opinion juris)* របស់ទ្រឹស្តីនេះជាភស្តុតាងដ៏ខ្លាំងដែលបង្ហាញឲ្យឃើញថាការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាទស្សនទានជាមូលដ្ឋានគ្រឹះមួយ នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌអន្តរជាតិ និងជាផ្នែកនៃច្បាប់ទម្លាប់អន្តរជាតិ នៅមុនពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥។

## ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចត្រូវបានអនុវត្តនៅខាងក្រៅបរិបទស្តីពីជម្លោះប្រដាប់អាវុធអន្តរជាតិ

៤៦. ស.ព បានប្រកាន់យកគោលជំហរយ៉ាងជាប់លាប់មិនផ្លាស់ប្តូរថា មានជម្លោះប្រដាប់អាវុធអន្តរជាតិមួយនៅក្នុងអំឡុងពេលមួយដែល ការទទួលខុសត្រូវរបស់ថ្នាក់លើនឹងត្រូវបានគេយកទៅអនុវត្តយ៉ាងមានប្រសិទ្ធិភាព[91] ។ ថ្វីបើយ៉ាងនេះក៏ដោយ សូម្បីតែនៅក្នុងជម្លោះប្រដាប់អាវុធ ដែលពុំមានលក្ខណៈជាអន្តរជាតិក៏ដោយ ក៏ការទទួលខុសត្រូវរបស់ថ្នាក់លើធ្លាប់ជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ដែលមានអត្ថិភាពមកតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះទៅទៀត ។

៤៧. សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុងករណី *Hadžihasanović* បានលើកឡើងអំពីបញ្ហានីមួយៗនេះ ថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ អនុវត្តនៅក្នុងបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិដែរឬទេ ឬមួយយ៉ាងណា[92] ។ ជាចុងក្រោយបំផុត អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានសម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានជាសំខាន់ពាក់ព័ន្ធ

[90] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Čelebići*, កថាខ័ណ្ឌទី៣៤០ ។

[91] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ចុះថ្ងៃទី១៨ កក្កដា ២០០៧, D3, ERN 00147244-00147399, កថាខណ្ឌទី៤ ។

[92] សាលដីកាលើករណីរបស់ *Hadžihasanović* ស្តីពីបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ, កថាខណ្ឌទី ១០-៣១ ។

ទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង[93] ។ នៅក្នុងការពិចារណារបស់ខ្លួន អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់អំពីរបៀបដែលវាពុំត្រូវបានជំទាស់ថា "ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ នៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុងមួយ នាំឱ្យកើតមានជាការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល"[94] ។ ការហាមឃាត់ចំពោះអំពើទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណថាមានដើមកំណើតមកពីមាត្រា៣ ដែលដូចគ្នានឹងអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលត្រូវបានកត់សម្គាល់ថាធ្លាប់ត្រូវបាន "ទទួលស្គាល់ជាយូរមកហើយថាមានលក្ខណៈជាទម្លាប់"[95] ។

៤៨. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានថ្លែងថា"ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាសញ្ញាណទាំងមូលនៃការហាមឃាត់ ដាក់ដោយមាត្រា៣ ដែលដូចគ្នានឹងអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ជំទាស់ទៅនឹងការធ្វើអ្វីៗដ៏ជាក់លាក់មួយចំនួន ក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធផ្ទៃក្នុង"[96] ។ ពាក្យអត្ថាធិប្បាយធ្វើឡើងដោយ ICRC ក្នុងឆ្នាំ១៩៥២ ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ ថាតើជម្លោះប្រដាប់អាវុធផ្ទៃក្នុងមួយមានអត្ថិភាព ឬមួយយ៉ាងណានោះត្រូវបានដកស្រង់សម្តីដោយបានលើកឡើងថាត្រូវតែមាន "ភាគីដែលបះបោរមាន "កងកម្លាំងយោធាមួយដែលបានរៀបចំ, *ដែលជាអាជ្ញាធរមួយទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន [...]* ដោយមានមធ្យោបាយផ្សេងៗ ក្នុងការធានា និងគោរព" អនុសញ្ញា"[97] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា "ការបញ្ជាដោយមានការទទួលខុសត្រូវ បង្កប់ន័យថាជា ការទទួលខុសត្រូវរបស់ថ្នាក់លើ"[98] ។ នៅក្នុងការចាត់ថាការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ត្រូវបានអនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុង មាត្រា៣ ដែលដូចគ្នានឹងអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដូច CIL ត្រូវតែមានយន្តការមួយដើម្បីដាក់ឱ្យប្រតិបត្តិនូវការដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មពាក់ព័ន្ធនានា[99] ។ វាមិនមានភាពរលូននឹងគ្នាទេរវាងកម្មវត្ថុ និងគោលបំណង (object and purpose) នៃអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ជាពិសេស មាត្រា៣ ដែលដូចគ្នានោះ គឺពុំមាន

[93] ដដែលដូចខាងលើ, កថាខណ្ឌទី៣១ ។

[94] ដដែលដូចខាងលើ, កថាខណ្ឌទី១២ ។

[95] ដដែលដូចខាងលើ, កថាខណ្ឌទី១៣-១៦ ។

[96] ដដែលដូចខាងលើ, កថាខណ្ឌទី១៥ ។

[97] សាលដីកាលើករណីរបស់ *Hadžihasanović* ស្តីពីបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ, កថាខណ្ឌទី ១៥ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*) ។ Jean S. Pictet, ពាក្យអត្ថាធិប្បាយ, អនុសញ្ញាទីក្រុងហ្សឺណែវទីI (ទីក្រុងហ្សឺណែវ, ឆ្នាំ១៩៥២), ទំព័រទី៤៩ ។

[98] សាលដីកាលើករណីរបស់ *Hadžihasanović* ស្តីពីបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ, កថាខណ្ឌទី១៥-១៧ ។

[99] ដដែលដូចខាងលើ, កថាខណ្ឌទី១៥-១៨ ។

ទម្រង់នៃការទទួលខុសត្រូវចំពោះការរំលោភលើច្បាប់ និងទម្លាប់នៃសង្គ្រាម ដែលត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុងមួយ[100] ។

៤៩. ដូចដែលបានកត់សម្គាល់ដោយដើមបណ្ដឹងឧទ្ធរណ៍[101] ពិធីសារបន្ថែមទីII មិនមានដាក់បញ្ចូលនូវបញ្ញត្តិជាក់លាក់ណាមួយស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើទេ ។ ទោះជាយ៉ាងនេះក៏ដោយក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានលើកឡើងអំពីបញ្ហានេះដូចដែលពួកគាត់បានរៀបរាប់នៅក្នុងភាសាផ្ដើមដំបូងក្នុងមាត្រា១.១ នៃពិធីសារបន្ថែមទីII ដែលត្រូវបានយោងយ៉ាងច្បាស់លាស់ដោយភាសាស្រដៀងគ្នាផងដែរ ដូចជា *"ការបញ្ជាដោយមានការទទួលខុសត្រូវ"*[102] ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថា ការខកខានពុំបានយោងទៅដល់ការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងពិធីសារបន្ថែមទីII គឺវាពុំបានបង្ហាញឱ្យបានច្បាស់លាស់ទេថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមានអត្ថិភាពនៅក្នុង CIL ដូចដែលបានអនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុងទេ[103] ។ តុលាការបានពិចារណាថា៖

> [វា]ពុំមានអ្វីនៅនឹងមុខធាតុផ្សំនានា[នៃការទទួលខុសត្រូវរបស់ថ្នាក់លើ]ដែលនឹងស្នើឡើងថា[វា]ត្រូវបានកំរិតនៅត្រឹមតែប្រភេទជាក់លាក់មួយនៃជម្លោះប្រដាប់អាវុធនោះទេ ឬថាវាតម្រូវឱ្យមានការចាំបាច់ជាមុនណាមួយនៃយុត្តាធិការនោះឡើយ ។ របៀបដែលធាតុផ្សំ

---

[100] អនុសញ្ញាទីក្រុងវីយ៉ែន, មាត្រា១៨ ។ ស្រដៀងគ្នានេះ គឺមិនអនុញ្ញាតឱ្យមានការអនុវត្តន៍នូវការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះការរំលោភច្បាប់ និងទម្លាប់នៃសង្គ្រាមនឹងពុំត្រូវគ្នាទៅនឹងគោលការណ៍នូរីមប៊ែរទេ ជាពិសេសគោលការណ៍ទី I ដែលបានផ្ដល់នូវការទទួលខុសត្រូវរបស់ថ្នាក់លើ សម្រាប់បុគ្គលដែលពាក់ព័ន្ធនឹងការរំលោភច្បាប់អន្តរជាតិ ។ គោលការណ៍នូរីមប៊ែរ, គោលការណ៍ទី I ។

[101] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី៦០ ។

[102] ពិធីសារបន្ថែមទៅនឹងអនុសញ្ញានានានៃទីក្រុងហ្សឺណែវថ្ងៃទី១២ សីហា ១៩៤៩ និងពិធីសារពាក់ព័ន្ធទៅនឹងកិច្ចការពារជនរងគ្រោះពីជម្លោះប្រដាប់អាវុធដែលពុំមែនជាលក្ខណៈអន្តរជាតិ (ពិធីសារទីII), ថ្ងៃទី៨ មិថុនា ១៩៧៧, 1125 U.N.T.S. 609 ។ "ពិធីសារនេះត្រូវអនុវត្តចំពោះជម្លោះប្រដាប់អាវុធទាំងអស់ដែលពុំត្រូវបានគ្របដណ្ដប់ដោយ ...[ពិធីសារទីI]... និងដែលកើតឡើងនៅលើទឹកដីរបស់ភាគីពាក់ព័ន្ធខ្លាំងក្នុងជម្លោះ រវាងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន និងកងកម្លាំងប្រដាប់អាវុធរបស់ពួកឧទ្ទាម ឬក្រុមប្រដាប់អាវុធដទៃទៀតដែលបានរៀបចំឡើង ដែលឋិតនៅក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើពួកខ្លួនបានអនុវត្តនូវការត្រួតត្រាទៅលើទឹកដីរបស់ភាគីខ្លួនដូចបានជួយសម្រួល និងគាំទ្រពួកគេឱ្យធ្វើប្រតិបត្តិការយោធានានា ហើយនិងអនុវត្តនូវពិធីសារនេះ" ។ *សូមមើលផងដែរ* សាលដីកាលើករណីរបស់ *Hadžihasanović* ស្ដីពីបណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ, កថាខណ្ឌទី ១៥-១៦ ។

[103] សាលដីកាលើករណីរបស់ *Hadžihasanović* ស្ដីពីបណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំ, កថាខណ្ឌទី ២៩ ("...មាត្រា៨៦ និង ៨៧ នៃពិធីសារទីI គឺ...មានតែការប្រកាសអំពីអត្ថិភាពនៃជំហរ ហើយពុំមែនអំពីការបង្កើតវាទេ ។ តាមរបៀបដូចគ្នានេះ ការមិនយោងសេចក្ដីនៅក្នុងពិធីសារទីII ចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធផ្ទៃក្នុង គឺមិនចាំបាច់មានការប៉ះពាល់ទៅនឹងសំនួរថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ មានអត្ថិភាពតាំងពីមុនជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធផ្ទៃក្នុងដែរឬទេ ឬមួយយ៉ាងណានោះឡើយ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍យល់ឃើញថា ពេលដែលមានការពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ គឺវាយ៉ាងដូច្នេះហើយ ហើយថាសម្រាប់មូលហេតុមួយចំនួនណាក៏ដោយ សេចក្ដីសន្និដ្ឋាននេះពុំត្រូវបានច្រានចោលដោយកត្តាសំខាន់ៗសម្រាប់ភាពនៅស្ងៀមស្ងាត់ ដែលជួនកាលមានកើតឡើងហួសពីការធ្វើក្រមស្ដីពីចំណុចយល់ព្រមណាមួយនៅក្នុងការព្រាងឯកសារច្បាប់អន្តរជាតិមួយ ដែលបានទទួលយល់ព្រម") ។

ទាំងនេះត្រូវបានអនុវត្ត មានការបញ្ជាក់ពីលក្ខណៈនៃជម្លោះនោះ - ឬសូម្បីតែពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធមួយ - គឺពុំមែនជាកត្តាពាក់ព័ន្ធនោះទេ[104] ។

ដូច្នេះ ផ្ទុយពីសេចក្តីសំអាងរបស់ដើមបណ្តឹងឧទ្ធរណ៍ ពិធីសារបន្ថែមទីII មិនអាចយល់បានទេ ដោយសារការច្រានចោលមួយនៃគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលបានចុះជាក្រមនៅក្នុងពិធីសារបន្ថែមទីI ហើយការទទួលខុសត្រូវរបស់ថ្នាក់លើនេះ អាចត្រូវបានអនុវត្តចំពោះជម្លោះប្រដាប់អាវុធផ្ទៃក្នុង ។

## ការទទួលខុសត្រូវលើការបញ្ជា អនុវត្តចំពោះពួកថ្នាក់លើជាយោធា និងជាស៊ីវិល

៥០. ដើមបណ្តឹងឧទ្ធរណ៍ លើកឡើងថាទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនេះ មិនអនុវត្តចំពោះមេដឹកនាំស៊ីវិលទេ[105] ។ នេះគឺជាការបកស្រាយខុសមួយទៅលើច្បាប់ ។ ការបកស្រាយរបស់តុលាការ ICTR, ICTY, SCSL និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ទៅលើច្បាប់ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ នៅទសវត្សរ៍ឆ្នាំ១៩៧០ គឺជំពាក់ទាក់ទងនឹងរយៈកាលខ្មែរក្រហម ពីព្រោះពុំមានការអភិវឌ្ឍន៍ធំដុំណាមួយនៅក្នុង CIL នៅក្នុងអំឡុងឆ្នាំនានាដែលបានធ្វើអន្តរាគមន៍នោះទេ[106] ។ មាត្រា ២៩ នៃច្បាប់ អវតក ដែលបានលើកឡើងពីការទទួលខុសត្រូវរបស់ថ្នាក់លើ គឺស្ទើរតែដូចគ្នាបេះបិទទៅនឹងបញ្ញត្តិដូចគ្នានេះ នៅក្នុងច្បាប់លក្ខន្តិកៈសម្រាប់តុលាការ ICTY, ICTR និង SCSL[107] ។

៥១. តុលាការ ICTY, ICTR និង SCSL បានតម្រូវឱ្យមានការបំពេញតាមធាតុផ្សំចំនួនបី ក្នុងគោលបំណងដើម្បីរកអ្នកប្រព្រឹត្តបទល្មើសឱ្យទទួលរ៉ាប់រងចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ៖ ទី១) ទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម, ទី២) ថ្នាក់លើបានដឹងឮ ឬមានហេតុផលថាខ្លួនបានដឹងឮថាអំពើឧក្រិដ្ឋហៀបតែនឹង ឬត្រូវបានប្រព្រឹត្ត, និងទី៣) ថ្នាក់លើខកខានពុំបានចាត់វិធានការ

---

104 សេចក្តីសម្រេចលើករណីរបស់ *Hadžihasanović* ស្តីពីបញ្ហាយុត្តាធិការ, កថាខណ្ឌទី៣០ ។

105 បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី៦៤-៦៥ ។

106 ពិធីសារបន្ថែមទីI ឆ្នាំ១៩៧៧ គឺជាការធ្វើក្រមមួយនៃច្បាប់ដែលកំពុងមានអត្ថិភាព ។ *សូមមើល* ពិធីសារបន្ថែមទីI, មាត្រា៨៦, ៨៧ ។

107 ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីកាត់សេចក្តីបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃអតីតប្រទេសយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ១៩៩១, ដូចដែលបានធ្វើវិសោធនកម្មដោយសេចក្តីសម្រេចលេខ ១៦៦០ របស់ក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី២៨ កុម្ភៈ ២០០៦, មាត្រា ៧.៣ [*ចាប់ពីនេះតទៅហៅថា៖* ច្បាប់លក្ខន្តិកៈសម្រាប់តុលាការ ICTY] ។ ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, ដូចដែលបានធ្វើវិសោធនកម្មដោយសេចក្តីសម្រេចលេខ ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី២៦ មិនា ២០០៤, មាត្រា ៦.៣ [*ចាប់ពីនេះតទៅហៅថា៖* ច្បាប់លក្ខន្តិកៈសម្រាប់តុលាការ ICTR] ។ ច្បាប់លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន, U.N.Doc.S/2002/ 246, 2178 U.N.T.S. 138 (2002) ឧបសម្ព័ន្ធទីII, មាត្រា៦.៣ ។

ចាំបាច់ ឬសមហេតុផលណាមួយដើម្បីរារាំងអំពើឧក្រិដ្ឋ ឬពុំបានដាក់ទណ្ឌកម្មដល់ចារី[108] ។ ការអនុវត្តន៍ធាតុផ្សំទាំងនេះពីសំណាក់តុលាការអន្តរជាតិ បានបញ្ជាក់ពីការបង្កើតរូបមន្តរបស់ អវតក ដោយបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពី CIL[109] ។

៥២. ដោយការទាញយកយុត្តាធិការពីក្រោយសង្គ្រាមលោកលើកទីពីរ តុលាការ ICTY និង ICTR បានបង្កើតនៅក្រោមច្បាប់ CIL ថាការទទួលខុសត្រូវរបស់ថ្នាក់លើ តម្រូវឱ្យមានទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម ដែលនៅក្នុងនោះ ថ្នាក់លើមាន "ការត្រួតត្រាដ៏មានប្រសិទ្ធិភាព" ទៅលើពួកថ្នាក់ក្រោមរបស់ខ្លួន ។ ថ្នាក់លើត្រូវតែមានការកាន់កាប់អំណាចយ៉ាងពិតប្រាកដ ឬជាដុំកំភួនក្នុងការត្រួតត្រាលើការប្រព្រឹត្តិរបស់ពួកថ្នាក់ក្រោម[110] ហើយថ្នាក់លើត្រូវតែមាន "លទ្ធភាពយ៉ាងសំខាន់ដើម្បីរារាំង ឬដាក់ទណ្ឌកម្មលើការប្រព្រឹត្តិ [...] បទល្មើសនានា"[111] ។ តុលាការ ICTY និង ICTR បានរកឃើញថារូបមន្តស្តីពីការត្រួតត្រាដ៏មានប្រសិទ្ធិភាពដែលអាចអនុវត្តបានចំពោះថ្នាក់លើទាំងតាមផ្លូវច្បាប់ និងទាំងតាមអង្គហេតុ (both *de jure* and *de facto)* ។ ការចាត់ទុកតាមផ្លូវការថាជា "មេបញ្ជាការ" ឬ "ថ្នាក់លើ" គឺពុំមានការចាំបាច់ទេសម្រាប់ភ្ជាប់ការទទួលខុសត្រូវ[112] ។

៥៣. នៅក្នុងការវាយតម្លៃអំពីសិទ្ធិអំណាចតាម*អង្គហេតុ (de facto)* តុលាការបានពិចារណាទៅលើកត្តាមួយចំនួន ដោយរួមទាំងថាតើការត្រួតត្រាដ៏មានប្រសិទ្ធិភាពត្រូវបានបង្ហាញតាមរយៈការមើលខុសត្រូវលើថ្នាក់ក្រោមរបស់ខ្លួន ដែរឬទេ, ថាតើថ្នាក់លើម្នាក់មានសិទ្ធិអំណាចក្នុងការចេញបញ្ជា

---

[108] *សូមមើល ឧទា.* សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៩៦ ។ *រដ្ឋអាជ្ញា ទល់នឹង Bagilishema*, សំណុំរឿងលេខ៖ ICTR-95-1A-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី៧ មិថុនា ២០០១, , កថាខណ្ឌទី៣៨ ។

[109] *សូមមើល* សាលដីកាសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ១៩៥ ("គោលការណ៍ដែលថ្នាក់លើជាយោធា និងជាអ្នកដទៃទៀតអាចនឹងត្រូវដាក់ឱ្យទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើនានារបស់ថ្នាក់ក្រោមរបស់ខ្លួន គឺត្រូវបានបង្កើតឡើងបានយ៉ាងល្អនៅក្នុងច្បាប់អនុសញ្ញា និងច្បាប់តាមទម្លាប់") ។ សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៣៣ ។ រដ្ឋអាជ្ញា ទល់នឹង *Blaškić*, សំណុំរឿងលេខ៖ IT-95-14-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២៩ កក្កដា ២០០៤, , កថាខណ្ឌទី ៨៥, ១៧៦ [*ចាប់ពីនេះតទៅហៅថា* ៖ សាលដីកាសម្រេចលើករណីរបស់ *Blaškić*] ។ រដ្ឋអាជ្ញា ទល់នឹង *Muvunyi*, សំណុំរឿងលេខ៖ ICTR-00-55A-T, សាលក្រម និងការផ្តន្ទាទោស, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១២ កញ្ញា ២០០៦, , កថាខណ្ឌទី ៤៧៣ ។ រដ្ឋអាជ្ញា ទល់នឹង *Kayishema* និង *Ruzindana*, សំណុំរឿងលេខ៖ ICTR-95-1-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២១ ឧសភា ១៩៩៩, , កថាខណ្ឌទី ២០៩, ២១៣ (គោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ គឺត្រូវបានបង្កើតឡើងយ៉ាងហ្មត់ចត់នៅក្នុងច្បាប់អន្តរជាតិ ហើយគោលជំហររបស់វាដែលដូចគ្នានឹងគោលការណ៍នៃច្បាប់តាមទម្លាប់អន្តរជាតិ ត្រូវបានគូសព្រាងនាពេលថ្មីៗនេះដោយតុលាការ ICTY) [*ចាប់ពីនេះតទៅហៅថា* ៖ សាលក្រមសម្រេចលើករណីរបស់ *Kayishema*] ។

[110] សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៧០ ("កត្តាដែលកំណត់ពីការរាំងរាំងសម្រាប់ទទួលខុសត្រូវប្រភេទនេះផ្នែកខាងព្រហ្មទណ្ឌ គឺការកាន់កាប់អំណាចជាក់ស្តែង ឬការមិនកាន់កាប់អំណាចក្នុងការការត្រួតត្រាទៅលើសកម្មភាពនានារបស់ថ្នាក់ក្រោម") ។

[111] *ដដែលដូចខាងលើ,* កថាខណ្ឌទី ៣៧៨ ។

[112] *សូមមើល ឧទា. ដដែលដូចខាងលើ,* កថាខណ្ឌទី ៣៥៤, ៣៧០ ។ *រដ្ឋអាជ្ញា ទល់នឹង Bagilishema*, សំណុំរឿងលេខ៖ ICTR-95-1A-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី៣ កក្កដា ២០០២, កថាខណ្ឌទី ៦១ ។

ទៅកាន់ថ្នាក់ក្រោមរបស់ខ្លួន ដែរឬទេ, ថាតើថ្នាក់លើម្នាក់បានបង្ហាញខ្លួនគាត់ចំពោះភាគីទីបីតាមរបៀបណា និងថាតើថ្នាក់លើម្នាក់មានសិទ្ធិអំណាចក្នុងការដាក់វិន័យទៅលើថ្នាក់ក្រោមរបស់ខ្លួនដែរឬទេ[113] ។ ថ្នាក់លើម្នាក់ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ មិនត្រឹមតែចំពោះការប្រព្រឹត្តិរបស់ពួកថ្នាក់ក្រោមបន្ទាប់ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងចំពោះសកម្មភាពនានារបស់ពួកថ្នាក់ក្រោមទៀតផង ឱ្យតែត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃការត្រួតត្រាដ៏មានប្រសិទ្ធិភាព[114] ។ ទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោមដែលត្រូវបានចោទប្រកាន់ក៏ពុំចាំបាច់ត្រូវមានលក្ខណៈជា អចិន្ត្រៃយ៍ផងដែរ[115] ។

៥៤. ដោយស្របគ្នានឹងការអនុវត្តន៍ ដែលបានឆ្លុះបញ្ចាំងនៅក្នុងសំណុំរឿងនានានៅក្រោយសង្គ្រាមលោកលើកទីពីរ ដូចជាករណីរបស់ *Brandt, Roechling* និង *Hirota* ជាដើម ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថាការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តចំពោះមេដឹកនាំជាស៊ីវិល ។ នៅក្នុងករណីរបស់ *Čelebići* អង្គជំនុំជម្រះបានសម្រេចថា "ថ្នាក់លើ ទោះជាទាហានក៏ដោយ ជាស៊ីវិលក៏ដោយ អាចត្រូវបានដាក់ឱ្យរ៉ាប់រងនៅក្រោមគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយមានមូលដ្ឋាននៅលើមុខតំណែងនៃសិទ្ធិអំណាចតាម *អង្គហេតុ* របស់ខ្លួន"[116]។ ដោយការទាញយកពីការវិភាគដ៏ទូលំទូលាយមួយរបស់អង្គជំនុំជម្រះសាលាដំបូង សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណីរបស់ *Čelebići* បានសម្រេចថា "គោលការណ៍ដែលថាថ្នាក់លើជាទាហាន ឬជាអ្នកដទៃទៀត អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើនានារបស់ថ្នាក់ក្រោម *គឺត្រូវបានបង្កើតឡើងបានយ៉ាងត្រឹមត្រូវនៅក្នុងច្បាប់អនុសញ្ញា និងច្បាប់តាមទម្លាប់*"[117] ។ ករណីយុត្តិសាស្ត្រស្រដៀងគ្នានេះក៏មាននៅក្នុងតុលាការ ICTR ផងដែរ[118] ។ ប្រការដែលសំខាន់នោះ គឺដូចជានៅតាមតុលាការនានានៅក្រោយសង្គ្រាមលោកលើកទី២ ហើយការអនុវត្តន៍ពីការទទួលខុសត្រូវរបស់ថ្នាក់លើនៅតាមថ្នាក់ជាតិជាបន្តបន្ទាប់មកទៀតនោះ[119] តុលាការ ICTY និង ICTR មិនបានធ្វើឱ្យមានការខុសប្លែកពីគ្នា រវាងបមាណីយ

---

113 *សូមមើល ឧទា. រដ្ឋអាជ្ញា ទល់នឹង Kajelijeli*, សំណុំរឿងលេខ៖ ICTR-98-44A-T, សាលក្រម និងការផ្តន្ទាទោស, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១ ធ្នូ ២០០៣, កថាខណ្ឌទី៤០៦ ។ សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៧៣៨, ៧៤៩-៥០, ៧៦៧។

114 *សូមមើល ឧទា. រដ្ឋអាជ្ញា ទល់នឹង Halilović*, សំណុំរឿងលេខ៖ IT-01-48-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៦ វិច្ឆិកា ២០០៥, កថាខណ្ឌទី ៦៣ ។

115 សាលដីកាសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ១៩៣ ។ *រដ្ឋអាជ្ញា ទល់នឹង Orić*, សំណុំរឿងលេខ៖ IT-03-68-T, សាលក្រម, ថ្ងៃទី៣០ មិថុនា ២០០៦, កថាខណ្ឌទី ៣១០ ។

116 សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៧៧ ។

117 សាលដីកាសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ១៩៥ (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*) ។

118 សាលក្រមសម្រេចលើករណីរបស់ *Kayishema*, កថាខណ្ឌទី ២១៣ ("ការអនុវត្តន៍នូវការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌចំពោះពួកស៊ីវិលដែលកាន់រក្សានូវសិទ្ធិអំណាចដែលតម្រូវឱ្យមាន គឺពុំមែនមានលក្ខណៈវិវាទគ្នានោះទេ") ។

119 *សូមមើលជាទូទៅ*, រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសអ៊ីស្រាអែល, *របាយការណ៍របស់គណៈកម្មាធិការស៊ើបអង្កេតស្តីពីព្រឹត្តិការណ៍ផ្សេងៗនៅតាមជំរុំជនភៀសខ្លួននានា នៅទីក្រុងបេរុត* - Kahan Commission Report, ថ្ងៃទី៨ កុម្ភៈ ១៩៨៣, *អាចរកបាននៅតាម*

ដែលត្រូវបានដាក់តម្រូវទៅលើពួកមេដឹកនាំជាទាហាន និងជាស៊ីវិល ឱ្យរ៉ាប់រងលើការទទួលខុសត្រូវរបស់ថ្នាក់លើទេ ហើយក៏ពុំមានការកំរិតអ្វីនៅក្នុងច្បាប់ អវតក អំពីភាពដែលអាចអនុវត្តពីការទទួលខុសត្រូវរបស់ថ្នាក់លើ បានតែចំពោះពួកមេដឹកនាំខាងយោធាប៉ុណ្ណោះនោះក៏ទេដែរ[120] ។

៥៥. តុលាការ ICTY បានបញ្ជាក់យ៉ាងច្បាស់លាស់ថា នៅក្នុងការដាក់ពួកថ្នាក់លើជាទាហាន និងជាស៊ីវិលនៅក្នុងបមាណីយដូចគ្នានេះ គឺថាពួកមេដឹកនាំជាស៊ីវិលអាចត្រូវបានឱ្យទទួលខុសត្រូវ "តែចំពោះវិសាលភាពដែលពួកគាត់បានអនុវត្តនូវកំរិតនៃការត្រួតត្រា ទៅលើថ្នាក់ក្រោមរបស់ពួកគាត់តែប៉ុណ្ណោះ ដែលនេះគឺជាការស្រដៀងគ្នាទៅនឹងពួកមេបញ្ជាការទាហាន"[121] ។ ច្បាប់លក្ខន្តិកៈនៃទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ក៏បានទទួលស្គាល់យ៉ាងជាក់ច្បាស់ផងដែរថា ការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវអនុវត្តចំពោះពួកមេដឹកនាំជាស៊ីវិលផងដែរ[122] ។ និយាយម្យ៉ាងវិញទៀត ដរាបណាឱ្យតែពួកមេដឹកនាំជាស៊ីវិល (ជាក់ស្តែងពួកមន្ត្រីជាន់ខ្ពស់របស់រដ្ឋ ដូចជា អៀង សារី ជាដើម) បង្ហាញថាមានកំរិតនៃការត្រួតត្រាទៅលើថ្នាក់ក្រោមរបស់គាត់ ដូចជាពួកដៃគូរបស់ខ្លួនដែលជាទាហាននោះពួកគាត់អាច ត្រូវបានដាក់ឱ្យរ៉ាប់រងទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានារបស់ថ្នាក់ក្រោមរបស់ខ្លួនបានហើយ ។

## ការទទួលខុសត្រូវលើការបញ្ជា និង ឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់

៥៦. ដើមបណ្តឹងឧទ្ធរណ៍ ជំទាស់ថាការអនុវត្តន៍ពីការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មនានាដែលមានចេតនាជាក់លាក់ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាដើម, ដោយបានលើកថាវាអាចនឹងនាំឱ្យមានការជំនុំជម្រះក្តីថ្នាក់លើណាម្នាក់ ដែលពុំមានការចាំបាច់ត្រូវមានចេតនាជាក់លាក់ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ[123] ។ ដើមបណ្តឹងឧទ្ធរណ៍ពុំបានពោលអះអាង ថាការកំរិតអំពីការទទួលខុសត្រូវរបស់ថ្នាក់លើបែបនេះមាននៅក្នុងច្បាប់ CIL ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

---

*វិបសាយ* http://www.mfa.gov.il/MFA/Foreign%20Relations/Israels%20Foreign%20Relations%20since%201947/1982-1984/104%20Report%20of%20the%20Commission%20of%20Inquiry%20into%20the%20e ។

[120] *សូមមើល ឧទា.* សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៧៧ ។ សាលក្រមសម្រេចលើករណីរបស់ *Kayishema*, កថាខណ្ឌទី ២១៣ ។

[121] សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៧៨ ។

[122] *សូមមើល* ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម, ថ្ងៃទី១៧ កក្កដា ១៩៩៨, មាត្រា ២៨.ក, ២៨.ខ.២ (ដើម្បីអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងបរិបទស៊ីវិល ឧក្រិដ្ឋកម្មនានាត្រូវតែមាន "សកម្មភាពដ៏គួរឱ្យព្រួយបារម្ភដែលឋិតនៅក្នុងរង្វង់នៃការទទួលខុសត្រូវ និងត្រួតត្រាដ៏មានប្រសិទ្ធិភាពពីសំណាក់ថ្នាក់លើ" ។ រីឯនៅក្នុងបរិបទយោធាវិញ ច្បាប់លក្ខន្តិកៈគ្រាន់តែបានចែងថា មេបញ្ជាការណាមួយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយ "កងកម្លាំងដែលឋិតនៅក្រោមកិច្ចបញ្ជា និងការត្រួតត្រាដ៏មានប្រសិទ្ធិភាពរបស់ខ្លួន" ប៉ុណ្ណោះ ។ [*ចាប់ពីនេះតទៅហៅថា៖* ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម] ។

[123] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៧៣-៧៤ ។

នោះឡើយ[124] ។ ដូច្នោះហើយ ស.ព សន្និដ្ឋានថាទឡ្ហីករណ៍នៃបណ្ដឹងឧទ្ធរណ៍នេះ គួរតែត្រូវបានបដិសេធចោល ពីព្រោះដើមបណ្ដឹងឧទ្ធរណ៍ពុំបានលើកសំអាងថា មានសក្ខីកម្មនៅក្នុងច្បាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលថាការទទួលខុសត្រូវរបស់ថ្នាក់លើមិនអនុវត្តចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់នោះឡើយ[125] ប៉ុន្តែផ្ទុយទៅវិញបែរជាលើកសំអាងជំទាស់នឹងការអនុវត្តន៍ទៅថ្ងៃខាងមុខ នូវការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្ម ដែលមានចេតនាជាក់លាក់នៅអ.វ.ត.កទៅវិញ។

៥៧. តុលាការ ICTY និងព្រមទាំងតុលាការ ICTR បានដាក់ឲ្យថ្នាក់លើទទួលខុសត្រូវចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាដើម របស់ពួកថ្នាក់ក្រោមរបស់ខ្លួន ហើយវាពុំមានអ្វីនៅក្នុងច្បាប់ CIL ដែលបញ្ជាក់ពីវិធានណាមួយដែលខុសគ្នាឡើយ[126] ។ តុលាការ ICTY បានសម្រេចថា "*បំណងឧក្រិដ្ឋ [mens rea]* សម្រាប់ដាក់ឲ្យថ្នាក់លើទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ [...] គឺពួកថ្នាក់លើបានដឹងឮ ឬមានហេតុផលក្នុងការបានដឹងឮថាថ្នាក់ក្រោមរបស់ខ្លួន៖ ទី១) ហៀបតែនឹង ឬ បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ហើយនិង ទី២) មានជាចាំបាច់នូវចេតនាជាក់លាក់ នេះ"[127] ។ ហេតុដូច្នេះ *បំណងឧក្រិដ្ឋ [mens rea]* ដែលបានតម្រូវឲ្យថ្នាក់លើរ៉ាប់រងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាការដឹងឮជាក់ស្ដែង ឬការដឹងឮដែលកើតឡើងដោយការបកស្រាយតាមផ្លូវច្បាប់៖ ថ្នាក់លើពុំចាំបាច់ត្រូវមានចេតនា[ប្រព្រឹត្ត]ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទេ[128] ។

## ការទទួលខុសត្រូវលើការបញ្ជា មិនតម្រូវឲ្យមានទំនាក់ទំនងហេតុផល រវាងឧក្រិដ្ឋកម្មដែលកំពុងមាន និង ការខកខាន[មិនបានប្រព្រឹត្ត]របស់ថ្នាក់លើទេ

---

[124] សហព្រះរាជអាជ្ញា មិនបានដឹងអំពីយុត្តិសាស្ត្រណាមួយដែលចុងចោទត្រូវបានគេកាត់សេចក្ដីពីបទប្រល័យពូជសាសន៍ ក្រោមទ្រឹស្ដីស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើ នៅមុនពេល ឬនៅក្នុងក្របខណ្ឌនៃអម្លុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩នោះទេ ។

[125] តាមពិត ដើមបណ្ដឹងឧទ្ធរណ៍មិនបានលើកឡើងសំអាងទៅលើយុត្តិសាស្ត្រណាមួយដែលកំណត់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តសម្រាប់ចេតនាឧក្រិដ្ឋជាក់លាក់មួយចំនួននោះឡើយ ។ បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី៧៣-៤ ។

[126] *សូមអាន រដ្ឋអាជ្ញា ទល់នឹង Brdanin,* សំណុំរឿងលេខ៖ IT-39-96-A, សាលដីកាសម្រេចលើករណីបន្ទាន់បង្ខំ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៩ មីនា ២០០៤, កថាខណ្ឌទី៧ (ដែលសំរេចថា ស្របគ្នាជាមួយនឹងសហកម្មឧក្រិដ្ឋកម្មរួមប្រភេទទី៣ ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺវា "មិនខុសគ្នាអ្វីពីទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌផ្សេងៗទៀត ដែលមិនតម្រូវឲ្យមានភស្តុតាងអំពីចេតនាក្នុងការប្រព្រឹត្តនូវឧក្រិដ្ឋកម្មណាមួយពីសំណាក់ជនជាប់ចោទនោះឡើយ មុនពេលការទទួលខុសត្រូវខាងព្រហ្មទណ្ឌអាចត្រូវយកមកភ្ជាប់") ។ សាលក្រមសម្រេចលើករណីរបស់ *Kayishema* , កថាខណ្ឌទី ២០៩ ។

[127] *រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic,* សំណុំរឿងលេខ៖ IT-02-60-T, សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ មករា ២០០៥, កថាខណ្ឌទី ៦៨៦ ។

[128] *ដដែលដូចខាងលើ, ប៉ុន្តែសូមមើល រដ្ឋអាជ្ញា ទល់នឹង Stakić,* សំណុំរឿងលេខ៖ IT-97-24-T, ដីកាសម្រេចលើវិធាន ៩៨ *ស្ទួន* ញត្តិស្នើសុំឲ្យ ចេញសាលក្រមដើម្បីលើកលែងទោស, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី៣១ តុលា ២០០២, កថាខណ្ឌទី ៩៤ ។

៥៨. ដើមបណ្តឹងឧទ្ធរណ៍ ជំទាស់ថាបើការទទួលខុសត្រូវរបស់ថ្នាក់លើ នឹងត្រូវបានអនុវត្តនៅ អវតក នោះទំនាក់ទំនងហេតុផលរវាងសកម្មភាពរបស់"ថ្នាក់លើ" និងឧក្រិដ្ឋកម្មនានារបស់ពួកថ្នាក់ក្រោមរបស់ខ្លួន គឺជាធាតុផ្សំមួយដែលត្រូវតែបានបង្ហាញជាសក្ខីកម្ម[129] ។ គាត់បានគាំទ្រសេចក្តីសន្និដ្ឋាននេះ ដោយយោងទៅដល់ករណីចំនួនពីរនាសម័យក្រោយសង្គ្រាមលោក និងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម[130] ។ ទោះជាយ៉ាងនេះក៏ដោយក៏ សព យល់ផ្ទុយពីនេះថាសេចក្តីគាំទ្រនេះខកខានពុំបានបង្ហាញសក្ខីកម្មថាច្បាប់ CIL ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ តម្រូវឱ្យមានការបង្ហាញពីទំនាក់ទំនងហេតុផលជាក់ស្តែង ឬប្រហាក់ប្រហែលរវាងសកម្មភាពរបស់"ថ្នាក់លើ" និងឧក្រិដ្ឋកម្ម។

៥៩. ករណីចំនួនពីរ នាសម័យក្រោយសង្គ្រាមលោក ដែលដើមបណ្តឹងឧទ្ធរណ៍បានរៀបរាប់ដោយខ្លួនឯងផ្ទាល់នោះ គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញពីអត្ថិភាពនៃធាតុផ្សំហេតុផលមួយ ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើទេ ។ តាមពិត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកំណត់សម្រេចនៅក្នុងករណីរបស់*Čelebići* ថាបើមានអត្ថិភាពនៃទ្រឹស្តីបែបទំនាក់ទំនងហេតុផលរវាងសកម្មភាពរបស់ថ្នាក់លើ និងការប្រព្រឹត្តឧក្រិដ្ឋកម្មមាននៅក្នុងច្បាប់CIL ហើយថា "ពុំបានរកឃើញថាមានការគាំទ្រណាមួយសម្រាប់អត្ថិភាពនៃលក្ខខណ្ឌតម្រូវស្តីពីសក្ខីកម្មនៃទំនាក់ទំនងហេតុផល ថាជាធាតុផ្សំដាច់ដោយឡែកណាមួយនៃការទទួលខុសត្រូវរបស់ថ្នាក់លើទេ ។ ហេតុដូច្នេះ អត្ថិភាពពិតប្រាកដនៃគោលការណ៍ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងការខកខានក្នុងការដាក់ទណ្ឌកម្មដែលត្រូវបានទទួលស្គាល់នៅក្រោមមាត្រា ៧.៣ [នៃច្បាប់លក្ខន្តិកៈសម្រាប់តុលាការ ICTY] និងច្បាប់តាមទម្លាប់ បានបង្ហាញថាអវត្តមាននៃលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងហេតុផល ថាជាធាតុផ្សំមួយដាច់ដោយឡែកមួយនៃទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ"[131]។សេចក្តីសន្និដ្ឋាននេះ ក៏ត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ផងដែរ[132] ។

៦០. ស.ព ជឿជាក់ថា នៅក្នុងបរិបទស្តីពីការខកខានរបស់ថ្នាក់លើដោយពុំបានរារាំងដល់ថ្នាក់ក្រោមពីហេតុផល ឬ ភាពជាប់គ្នា រវាងអំពើនានារបស់ថ្នាក់លើ និង/ឬ ការខកខាន ហើយនិងការប្រព្រឹត្តិឧក្រិដ្ឋកម្ម គឺមានការទាញសេចក្តីសន្និដ្ឋានដែលមាននៅក្នុងទ្រឹស្តីស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលជាជំហរមួយគាំទ្រមួយនៅក្នុងសាលក្រមសម្រេចលើករណីរបស់ *Čelebići*[133] ។ នៅពេលដែលគោលជំហរនេះ ទំនងជាមានការបញ្ជាក់ថា សកម្មភាពរបស់ថ្នាក់លើ និង ឧក្រិដ្ឋកម្ម

[129] បណ្តឹងឧទ្ធរណ៍, ទំព័រទី ២៧ ។

[130] *ដដែលដូចខាងលើ*, កថាខណ្ឌទី ៦៦-៦៨ ។

[131] *ដដែលដូចខាងលើ*, កថាខណ្ឌទី ៣៧៨, ៤០០ ។

[132] សាលដីកាសម្រេចលើករណីរបស់ *Blaškić*, កថាខណ្ឌទី ៧៦ ។

[133] សាលក្រមសម្រេចលើករណីរបស់ *Čelebići*, កថាខណ្ឌទី ៣៩៩ ("ទំនាក់ទំនងគ្នាទៅវិញទៅមករវាងហេតុនឹងផលដ៏ការចាំបាច់មួយអាចនឹងត្រូវបានពិចារណាថាមានជាប់មកជាមួយស្រាប់នៅក្នុងលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយថ្នាក់ក្រោមនានា ហើយនិងការខកខានរបស់ថ្នាក់លើក្នុងការចាត់វិធានការផ្សេងៗក្នុងរង្វង់នៃសិទ្ធិអំណាចរបស់ខ្លួនដើម្បីទប់ស្កាត់នូវឧក្រិដ្ឋកម្មទាំងនេះ") ។

ត្រូវតែមានទំនាក់ទំនងនឹងគ្នាពីចម្ងាយ គឺពុំមានភស្តុតាងទេ - តាមអង្គហេតុពិតជាក់ស្តែង ឬត្រូវបានផ្តល់ដោយដើមបណ្តឹងឧទ្ធរណ៍ - ដែលថាភាពនៅជិតគ្នា ឬសូម្បីតែទំនាក់ទំនងហេតុផលជាក់ស្តែងរវាងថ្នាក់លើ និងឧក្រិដ្ឋកម្ម គឺជាធាតុផ្សំវិជ្ជមានមួយដែលត្រូវតែបានបង្ហាញជាសក្ខីកម្មក្នុងគោលបំណងដើម្បីអនុវត្តពីការទទួលខុសត្រូវរបស់ថ្នាក់លើ ប្រឆាំងនឹងដើមបណ្តឹងឧទ្ធរណ៍ ។

៦១. ការអភិវឌ្ឍន៍វិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិនាពេលបច្ចុប្បន្ននេះ ដូចដែលមានច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមជាភស្តុតាងស្រាប់ ក៏បានបន្ថែមការគាំទ្រដល់សេចក្តីសន្និដ្ឋាននេះផងដែរ[134] ។ ផ្ទុយពីការបកស្រាយរបស់ដើមបណ្តឹងឧទ្ធរណ៍អំពីច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម និងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើ[135] ការដាក់បញ្ចូលវាក្យស័ព្ទ "ដែលជាលទ្ធផលនៃ - as a result" បានបញ្ជាក់ថាការខកខានរបស់ថ្នាក់លើក្នុងការរារាំង ត្រូវតែមានការពាក់ព័ន្ធគ្នាតាមរបៀបណាមួយទៅនឹងឧក្រិដ្ឋកម្មដែលកំពុងកើតឡើងនេះ[136] ។ ទោះជាយ៉ាងនេះក៏ដោយក៏ សចព ជឿជាក់ថាការវិវត្តន៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅឯតុលាការ ICC - ជាតុលាការមួយដែលមានសកម្មភាពក្នុងឆ្នាំ២០០២[137] - ពុំមានប៉ះពាល់ទេថាតើការទទួលខុសត្រូវរបស់ថ្នាក់លើ មាននៅក្នុងច្បាប់ CIL ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឬពុំមាននោះទេ ហើយជាពិសេសជាងនេះទៅទៀតនោះគឺថា បើទំនាក់ទំនងហេតុផលនោះវាជាធាតុផ្សំតាមទម្លាប់មួយនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងអំឡុងនៃរយៈពេលនោះ ។

## ៤.សេចក្តីសន្និដ្ឋាន និង ការស្នើរកដំណោះស្រាយ

៦២. ស.ព សូមស្នើថា បណ្តឹងឧទ្ធរណ៍នេះ គួរតែត្រូវបានប្រកាសថា ពុំអាចទទួលយកបានទេ និងមិនត្រូវបានអនុញ្ញាតឲ្យមាន ទៅតាមវិធាន ៧៤.៣.ក និង ២១ នោះទេ។

៦៣. បើអង្គបុរេជំនុំជម្រះ យល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបានវិញនោះ នោះក៏គួរតែពិចារណាលើសំអាងរបស់ដើមបណ្តឹងឧទ្ធរណ៍ស្តីពីអង្គសេចក្តីរបស់ពួកគាត់ដែល សចព បានធ្វើសេចក្តីសន្និដ្ឋានខាងដើមអំពីមូលហេតុដែលថា បណ្តឹងឧទ្ធរណ៍នេះគួរតែត្រូវបានបដិសេធចោល,

---

[134] ច្បាប់លក្ខន្តិកៈនៃទីក្រុងរ៉ូម, មាត្រា២៨.ក និង ខ ។

[135] ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា វាក្យស័ព្ទ "ដែលជាលទ្ធផល" ដែលបានដាក់បញ្ចូលនៅក្នុងច្បាប់លក្ខន្តិកៈនៃទីក្រុងរ៉ូមលើប្រធានបទស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ បង្ហាញឲ្យឃើញថា ការតភ្ជាប់គ្នានៃទំនាក់ទំនងហេតុផល រវាងសកម្មភាពរបស់ថ្នាក់លើ ហើយនិងការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ត្រូវតែបានផ្តល់ជាភស្តុតាងនៅក្នុងពេលសវនាការ ។ បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ៦៨ ។ សហព្រះរាជអាជ្ញាជឿជាក់ថា វាក្យស័ព្ទ "ដែលជាលទ្ធផល" គឺមិនមែនមានន័យថា ជាទំនាក់ទំនងគ្នាដោយផ្ទាល់រវាងហេតុនិងផល ដែលត្រូវផ្តល់ភស្តុតាងនោះទេ ។

[136] ច្បាប់ក្ខន្តិកៈនៃទីក្រុងរ៉ូម, មាត្រា២៨.ក និង ខ ។

[137] គេហទំព័រស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, *ច្បាប់លក្ខន្តិកៈនៃទីក្រុងរ៉ូម,* អាចរកបានតាមអាសយដ្ឋាន:http:\www.icc-cpi.int/Menus/ICC/Legal+Texts+and+Tools/Official+Journal/Rome+ Statute.htm (ដែលចូលជាធរមានកាលពីថ្ងៃទី១ កក្កដា ២០០២) ។

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦០)*

ការច្រានចោលញត្តិស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ របស់ សចស ត្រូវតែតម្កល់ទុក ហើយ ការទទួលខុសត្រូវរបស់ថ្នាក់លើ គួរតែត្រូវបានប្រកាសថា អាចអនុវត្តបាននៅ អ.វ.ត.ក ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | | [signature] |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |